ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែឧសភា ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១១១



# ពលរដ្ឋថា៖ បើមិនទៅបោះឆ្នោតគឺ ជាការបំបាត់សិទ្ធិសេរីភាពខ្លួនឯង

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខ៖ ០២០/១៨ ព.ម.រ.ល.អ/ ០១-មករា-២០១៨



# លិខិតជូនពរ

## លោកអភិបាល អូលីវីយេ ឝ្មីតអឺស្ល៊ែរ

ក្នុងឱកាសខួបកំណើត៤៨ឆ្នាំចូល៤៩ឆ្នាំ និងខួប២០ឆ្នាំនៃអគ្គសញ្ញាតែងតាំងជាបូជាចារ្យ
យើងខ្ញុំទាំងអស់គ្នាជាគ្រីស្តបរិស័ទទាំងអស់ សូមអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ជាព្រះបិតា
ប្រទានព្រះពរដល់លោកអភិបាល សូមឲ្យលោកមានកម្លាំងកាយ កម្លាំងចិត្ត និងពោរពេញ
ដោយប្រាជ្ញាញាណ ដើម្បីអនុវត្តតាមការត្រាស់ហៅរបស់ព្រះអង្គក្នុងការប្រកាសដំណឹងល្អ
និងបន្តណែនាំ យើងខ្ញុំក្នុងមាគ៌ានៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ តាមគំរូរបស់
ព្រះយេស៊ូជាអម្ចាស់។

# កម្ពុជាប្រកាសបោសសំអាតមីនឲ្យអស់នៅ ឆ្នាំ២០២៥




ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនឆ្នាំ២០១៨-២០២៥ដើម្បីបោសសំអាតមីននៅក្នុងប្រទេសឲ្យអស់ ត្រូវបានប្រកាសដាក់ឲ្យអនុវត្តកាលពីថ្ងៃទី១៧ ខែឧសភាឆ្នាំ២០១៨នៅវិមានសន្តិភាព។

ផែនការនេះត្រូវបានប្រកាសដោយសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងពិធីបិទសន្និបាតជាតិវិស័យសកម្មភាពមីន ក្រោមប្រធានបទ "ឆ្ពោះទៅរកកម្ពុជាមួយ ដែលគ្មានមីននៅឆ្នាំ២០២៥"។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា កេរដំណែលគ្រាប់មីន និងសំណល់ជាតិផ្ទុះនៅកម្ពុជា ត្រូវបានបន្សល់ទុកពីសម័យសង្គ្រាម និងជម្លោះផ្ទៃក្នុងរាប់ទសវត្សរ៍ បានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសដែលទទួលរងផលប៉ះពាល់ និងមានជនរងគ្រោះដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមច្រើនជាងគេបំផុតក្នុងពិភពលោក។ សម្តេចតេជោបានមានប្រសាសន៍ទៀតថា តាមរយៈប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០១៧ មានជនរងគ្រោះចំនួន៦៤.៦៨៨នាក់។

សម្តេចតេជោ ហ៊ុន សែន បានបន្តថា កម្ពុជាតែងបានខិតខំរិះរកមធ្យោបាយដើម្បីដោះស្រាយបញ្ហា នេះរហូតឈានដល់ការគ្រប់គ្រងបានយ៉ាងល្អប្រសើរនូវការងារបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមនិងការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីនដែលបានទាញឲ្យចំនួនគ្រោះថ្នាក់ធ្លាក់ចុះជាប្រចាំ។ ជាក់ស្តែងជនរងគ្រោះបានថយចុះយ៉ាងខ្លាំងពី ៤.៣២០នាក់ នៅក្នុងឆ្នាំ១៩៩៦ មកនៅចំនួនប្រហែល១០០នាក់ក្នុងមួយឆ្នាំជាមធ្យមក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

សម្តេចតេជោ ហ៊ុន សែន បានបន្តថា ដើម្បីដោះស្រាយបញ្ហានេះ ចាប់ពីក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ក្នុងនាមជាថ្នាក់ដឹកនាំមួយរូបសម្តេចបានខិតខំពុះពារយ៉ាងលំបាកជម្នះគ្រប់ឧបសគ្គ ដើម្បីបង្រួបបង្រួមប្រទេសជាតិ រកសន្តិភាពនិងបញ្ចប់សង្គ្រាមជូនប្រទេស និងប្រជាជនកម្ពុជា ដែលក្នុងពេលនោះដៃម្ខាងត្រូវប្រយុទ្ធទប់ស្កាត់ មិនឲ្យរបបប៉ុលពតវិលមកវិញ ហើយដៃម្ខាងទៀតខិតខំស្តារសង្គម សេដ្ឋកិច្ចក្នុងស្ថានភាព ដែលប្រទេសជាតិស្ថិតក្នុងស្ថានភាពហ៊ុមព័ទ្ធខាងនយោបាយនិងសេដ្ឋកិច្ចពីខាងក្រៅយ៉ាងអយុត្តិធម៌ទៀតផង។ តាមរយៈការអនុវត្តនយោបាយ"ឈ្នះ-ឈ្នះ" កម្ពុជាទទួលបានសន្តិភាពពេញលេញទូទាំងប្រទេស បញ្ចប់សង្គ្រាមរ៉ាំរ៉ៃរាប់ទសវត្សរ៍ អង្គការចាត់តាំងខាងនយោបាយ និងយោធារបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានរំលាយ ហើយប្រទេសជាតិក៏ទទួលបានមកវិញនូវសុខសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដីដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រជាង ៥០០ ឆ្នាំ នៅកម្ពុជា។ បច្ចុប្បន្ននេះប្រជាជនកម្ពុជាពិតជាបានឃើញយ៉ាងច្បាស់អំពីការអភិវឌ្ឍសង្គមជាតិ ការរីកចម្រើនលើគ្រប់វិស័យដែលកើតចេញពីគុណតម្លៃនៃសុខសន្តិភាពនេះ។ ក្នុងន័យនេះ បានបង្ហាញថាប្រជាជនកម្ពុជាម្នាក់ៗ បានយល់ច្បាស់ណាស់ពីមហាវិនាសកម្មដោយសារសង្គ្រាមដូចមានក្នុងប្រវត្តិសាស្ត្ររបស់ខ្លួនថ្មីៗនេះ ហើយតែងតែបានប្តេជ្ញាចិត្តខ្ពស់ទោះបីក្នុងតម្លៃណាក៏ដោយមិនឲ្យបាត់បង់ទៅវិញជាដាច់ខាតនូវសុខសន្តិភាពនេះ ពីព្រោះលទ្ធផលនៃសន្តិភាពនេះ បានរួមចំណែកយ៉ាងខ្លាំងក្លាដល់ការបន្ថយគ្រោះថ្នាក់ដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះ កិច្ចដំណើរការពង្រឹងលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិកម្ពុជា។

នៅថ្ងៃនោះដែរ សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ បដិសេធចំពោះការលើកឡើងពីអ្នកបកស្រាយ ឬសារព័ត៌មានមួយចំនួនដែលលើកឡើងថា "គ្រាប់មីននៅកម្ពុជាស្អុយអស់ហើយ"។ សម្តេចតេជោ សូមកុំឲ្យមានការលើកឡើងបែបនេះ ពីព្រោះការនិយាយបែបនេះធ្វើឲ្យមានការភាន់ច្រឡំ និងខ្វះការប្រុងប្រយ័ត្នពីប្រជាពលរដ្ឋ ពីព្រោះគ្រាប់មីនមិនស្អុយនោះទេ វាអាចបង្កគ្រោះថ្នាក់គ្រប់ពេលវេលា។

គួររំលឹកថារយៈពេល ២៥ឆ្នាំ ពីឆ្នាំ១៩៩២ដល់២០១៧ ប្រតិបត្តិការដោះមីននៅកម្ពុជាបានបោសសំអាតមីនប្រឆាំងមនុស្សចំនួន ១,០៣ លានគ្រាប់ មីនប្រឆាំងរថក្រោះចំនួន ២៤.២៥១ និង គ្រាប់មិនទាន់ផ្ទុះចំនួន ប្រមាណជា ២,៦៦ លានគ្រាប់ ។

យោងតាមរបាយការណ៍របស់អាជ្ញាធរមីន និងសកម្មភាពជួយជនរងគ្រោះដោយមីនកម្ពុជាបានឱ្យដឹងថា ដើម្បីលុបបំបាត់គ្រាប់មីននៅកម្ពុជា សកម្មភាពនេះបានចំណាយប្រាក់៦៣៣លានដុល្លារអាមេរិក (១៦០លានដុល្លារជាថវិកាជាតិនិង៤៧លានដុល្លារជាជំនួយពីសហគមន៍អន្តរជាតិនានា)។ជាមួយនឹងទឹកប្រាក់នេះកម្ពុជាបានបោសសំអាតផ្ទៃដីមីនប្រមាណជា១.៧០០គីឡូម៉ែត្រក្រឡា ហើយរំពឹងថានឹងអាចរំដោះផ្ទៃដីដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះប្រមាណជា២.០០០គីឡូម៉ែត្រក្រឡាទៀតនៅមុនឆ្នាំ២០២៥៕ *ដោយអរិយបុត្រ*

# រដ្ឋាភិបាលបែងចែកឆ្នេរជា៥ប្រភេទ ប៉ុន្តែពលរដ្ឋថាជារឿងមិនសំខាន់

ក្រសួងទេសចរណ៍បានប្រកាសកាលពីពេលថ្មីៗនេះថា រាជរដ្ឋាភិបាលបានសម្រេចបែងចែកឆ្នេរសមុទ្រនៅក្នុងប្រទេសជា៥មានឆ្នេរអភិរក្សស្តូល ឆ្នេរអេកូទេសចរណ៍ ឆ្នេរកម្សាន្តពិសេស ឆ្នេរកម្សាន្តសាធារណៈកម្រិតខ្ពស់ និងកម្រិតមធ្យម ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ពលរដ្ឋថា វាមិនសំខាន់សម្រាប់ពួកគាត់ទេ។ អ្វីសំខាន់អាជ្ញាធរត្រូវតែធានារឿងបរិស្ថានល្អ ការគ្រប់គ្រងល្អ ហើយជាពិសេសគឺរឿងតម្លៃនៃសេវាកម្មនៅតាមតំបន់ឆ្នេរទាំងនេះ ហើយថា តើពលរដ្ឋអាចទៅលេងនៅទីនោះបានដោយសេរីឬយ៉ាងណា?

លោក ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានថ្លែងបែបនេះ នៅក្នុងសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃការអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជា ក្នុងនាមជាសមាជិកក្លិបឆ្នេរសមុទ្រស្អាតបំផុតលើសកលលោក នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ នៅសណ្ឋាគារឆ្នេរឯករាជ្យ ខេត្តព្រះសីហនុ ដោយលោកប្រ៊ុយណូ បូជាត អគ្គនាយកក្លិបឆ្នេរសមុទ្រស្អាតបំផុតលើសកលលោក និងមានការចូលរួមពីអភិបាលខេត្តតំបន់ឆ្នេរទាំង៤ រួមនិងមន្ទីរពាក់ព័ន្ធក្នុងខេត្តជាប់សមុទ្រទាំង៤ មានខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប និងខេត្តកោះកុង។

លោករដ្ឋមន្ត្រីបានលើកឡើងពីការគ្រប់គ្រងឆ្នេរខ្សាច់កម្សាន្តថា ស្របតាមអនុសាសន៍របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលបានស្នើឱ្យក្រសួងទេសចរណ៍រៀបចំឆ្នេរ ដើម្បីធានាឱ្យសកម្មភាពទេសចរណ៍ តាមបណ្តោយឆ្នេរសមុទ្រ គោរពតាមបទដ្ឋានបរិស្ថានសំដៅធានាឲ្យឆ្នេរ សមុទ្រកម្ពុជាកាន់តែស្រស់ស្អាត មានអនាម័យ និងសណ្តាប់ធ្នាប់ ប្រកបដោយភាពទាក់ទាញ ដើម្បីឆ្លើយតបនឹងការយកចិត្តទុកដាក់អំពីទស្សនាទានបៃតងនៅកម្ពុជា។

ទាក់ទិននឹងការអភិវឌ្ឍឆ្នេរនេះ លោក ប្រ៊ុយណូ បូជាត បានធ្វើការវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់ខេត្តតំបន់ឆ្នេរ ដែលមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស រួមមានហេដ្ឋារចនាសម្ពន្ធផ្លូវថ្នល់ សំណង់អាគារ សណ្ឋាគារ ភោជនីយដ្ឋាន និងសម្បទារផ្សេងទៀតជាច្រើន ពិសេសការរក្សាបាននូវការការពារធនធានធម្មជាតិតំបន់ឆ្នេរ សោភ័ណភាព បរិស្ថាន អនាម័យ និងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋមូលដ្ឋានជាដើម។

តាមសេចក្តីរាយការណ៍របស់ក្រសួងទេសចរណ៍ លោក ប្រ៊ុយណូ បូជាត ក៏បានបំពេញទស្សនកិច្ចនៅតាមខេត្តនៅតំបន់ឆ្នេរទាំងបួនរបស់កម្ពុជា ពីថ្ងៃទី០១ ដល់ ០៥ ខែឧសភា។ បន្ទាប់ពីទស្សនកិច្ចនោះ លោក ក៏បានធ្វើការកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានរៀបចំពីធីបុណ្យសមុទ្រ នាពេលកន្លងមកទទួលបានជោគជ័យ និងទទួលបាននូវការគាំទ្រពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាតំបន់ឆ្នេរសមុទ្រកម្ពុជាឲ្យមានចំនួនកាន់តែច្រើនឡើង។ លោក ក៏បានបង្ហាញពីសុទិដ្ឋិនិយម ចំពោះគម្រោងអភិវឌ្ឍនានា ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា ពិសេសគម្រោងសាងសង់ផ្លូវថ្នល់ល្បឿនលឿនភ្ជាប់ពីរាជធានីភ្នំពេញមកកាន់តំបន់ឆ្នេរ និងការដាក់ចេញនូវចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ និងបដិសណ្ឋារកិច្ចល្អ" ជាដើម។

ទាក់ទិននឹងការអភិវឌ្ឍតំបន់ឆ្នេរនេះដែរ លោក ថោង ខុន ក៏បានស្នើសុំកិច្ចសហការជាមួយរដ្ឋបាលខេត្តជាប់ឆ្នេរសមុទ្រទាំង ៤ ឲ្យមានសួនទេសចរណ៍ឲ្យបានយ៉ាងហោចណាស់មួយនៅក្នុងមួយខេត្ត។ លោកបានបន្តថា កម្ពុជាក៏មានស្តង់ដារ "សួនទេសចរណ៍" រួចហើយដែរ។

លោកក៏បានសង្កត់ធ្ងន់លើការងាររៀបចំក្រុមការងារទទួលបន្ទុកគ្រប់គ្រងឆ្នេរសមុទ្រ ការគ្រប់គ្រងសំណង់រឹងនិងរាវព្រមទាំងគុណភាពទឹកសមុទ្រ ការថែរក្សាភាពស្អាតការបំពាក់ធុងសំរាមដែលមានការបែងចែកនិងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវនៅតាមទីតាំងអាជីវកម្មដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍតំបន់ឆ្នេរប្រកបដោយនិរន្តរភាព ការធានាដល់ការរីកចម្រើនធុរកិច្ចរបស់ខ្លួនផង និងសង្គមជាតិទាំងមូលផង។

ជុំវិញការបែងចែកតំបន់ឆ្នេរជាប្រាំប្រភេទនេះ ប្រជាពលរដ្ឋកម្ពុជាបានស្វាគមន៍ ប៉ុន្តែទោះបីជាយ៉ាងណា ពួកគាត់សុំឲ្យអាជ្ញាធរត្រូវតែធានាឲ្យបានបរិស្ថានល្អ ការគ្រប់គ្រងល្អ ហើយជាពិសេសគឺរឿងតម្លៃនៃសេវាកម្មនៅតាមតំបន់ឆ្នេរទាំងនេះ ។

លោក រិន វាសនា ជាប្រជាពលរដ្ឋវ័យ៤៥ឆ្នាំបានឲ្យដឹងថា នេះគឺជាការល្អដែរ ដើម្បីធានាឲ្យឆ្នេរយើងស្អាត ប៉ុន្តែបែងចែកយ៉ាងណានោះ គឺជាកិច្ចការអាជ្ញាធរ តែអ្វីដែលពួកគាត់ជាប្រជាពលរដ្ឋចាប់អារម្មណ៍មុនគេនោះ គឺឆ្នេរយើងស្អាត គ្មានសំរាម មានបរិស្ថានល្អ ហើយជាពិសេសរឿងតម្លៃសេវាកម្មផ្សេងៗ។

លោកបានបញ្ជាក់ថា "ចង់ថាឆ្នេរនោះជាឆ្នេរអ្វីមិនសំខាន់ទេ។ ខ្ញុំមិនសូវចាប់អារម្មណ៍ទេ អ្វីដែលសំខាន់គឺថា យើងអាចទៅលេងបានអត់ ហើយបើទៅ ថាតើតម្លៃតូប តម្លៃអាហារ ហើយរៀបរយបរិស្ថានល្អយ៉ាងណា បានវាសំខាន់"។

លោក ទេព សុផាន់ ដែលជាប្រជាពលរដ្ឋអាយុ៤២ឆ្នាំមួយរូប បានឲ្យដឹងថា បែងចែកនេះក៏វាល្អដែរ ប៉ុន្តែសួរថាក្រោយពេលបែងចែកហើយ តើពលរដ្ឋអាចមានសិទ្ធិទៅលេងកម្សាន្តនៅតាមឆ្នេរទាំងនេះដោយសេរី ដោយមិនអស់លុយអស់កាក់ទិញសំបុត្របានឬអត់? ព្រោះល្បីថា ឆ្នេរសាធារណៈមួយចំនួនដូចជាក្លាយជារបស់សណ្ឋាគារ ក្លាយជារីសតអស់ហើយ។

នៅឆ្នាំ២០១៧កម្ពុជា មានទេសចរអន្តរជាតិជាង ៥.៦លាននាក់ កើន ១១.៨% ដែលបានប្រាក់ចំណូលប្រមាណ ៣,៤០០លានដុល្លារ រួមចំណែកប្រមាណ ១៣% នៃផលិតផលក្នុងស្រុកសរុប(GDP)និងផ្តល់ការងារដោយផ្ទាល់ជាង ៦២ម៉ឺននាក់ និងដោយប្រយោលរាប់សិបម៉ឺននាក់ទៀត។ ក្នុងរយៈពេល ២ខែដើមឆ្នាំ២០១៨ កម្ពុជាទទួលបានទេសចរអន្តរជាតិ ១.១លាននាក់ កើន ១១%។ តាមការព្យាករណ៍ កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ ៦.១លាននាក់នៅឆ្នាំ២០១៨ និងប្រមាណ ១០លាននាក់ នៅឆ្នាំ២០២៥។ នៅឆ្នាំ២០៣០ កម្ពុជានឹងទទួលបានទេសចរអន្តរជាតិប្រមាណ១៥លាននាក់ជាមួយនឹងការផ្តល់ចំណូលប្រមាណ១០ពាន់លានដុល្លារ និងផ្តល់ឱកាសការងារដោយផ្ទាល់ប្រមាណ២លាននាក់ និងប្រយោលរាប់លាននាក់បន្ថែមទៀត។

ដោយឡែកក្នុងឆ្នាំ២០១៧ តំបន់ឆ្នេរសមុទ្រកម្ពុជា ទទួលបានទេសចរអន្តរជាតិប្រមាណ៧៤ម៉ឺននាក់កើន ១៥%។ ក្នុងរយៈពេល៤ខែដើមឆ្នាំ២០១៨ តំបន់ឆ្នេរសមុទ្រកម្ពុជាទទួលបានភ្ញៀវទេសចរ ២.៣៨៥.៧៥៣នាក់ ដែលក្នុងនោះភ្ញៀវទេសចរជាតិមាន ២.០៥២.៣១៧នាក់ និងអន្តរជាតិមាន៣៣៣.៤៣៦នាក់ កើនបាន ១៦,៣៧%។ តាមការព្យាករណ៍ តំបន់ឆ្នេរសមុទ្រកម្ពុជាទាំងមូលអាចទទួលបានភ្ញៀវអន្តរជាតិ២លាននាក់ និងភ្ញៀវជាតិប្រមាណ៦លាននាក់នៅឆ្នាំ២០២០។


ថតដោយៈ សុធីរិទ្ធ

ដោយអរិយបុត្រ

# តើបណ្ណាការថ្លៃ ពិតជាជួយលើកកិត្តិយសពេលរៀបអាពាហ៍ពិពាហ៍មែនទេ ?

ប្រាក់ថ្លៃបណ្ណាការ បានក្លាយជារឿងដែលយុវជនភាគច្រើនមានកង្វល់ ខណៈចូលស្តីដណ្តឹងយុវនារីមកធ្វើជាភរិយានោះ នាយិកាអង្គការសង្គមស៊ីវិលមួយរូបមិនគាំទ្រនោះទេ ហើយចាត់ទុកថា ការបង្គាប់ថ្លៃបណ្ណាការខ្ពស់ពេក គឺប្រៀបបាននឹងការលក់កូនស្រីរបស់ខ្លួនទៅវិញ។

លោកស្រីរស់ សុភាព នាយិកាអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា មានប្រសាសន៍ថា លោកស្រីទទួលស្គាល់ថា ក្នុងពិធីមង្គលការមួយ គឺត្រូវចំណាយប្រាក់អស់ច្រើន ក៏ប៉ុន្តែការទារថ្លៃបណ្ណាការកប់មេឃទៅខាងប្រុស វានឹងធ្វើឲ្យស្ត្រីក្លាយជាជនរងគ្រោះដោយមិនដឹងខ្លួន។ លោកស្រីចាត់ទុកថា ការបង្គាប់ថ្លៃបណ្ណាការខ្ពស់ គឺស្មើនឹងការលក់កូនស្រីហើយវាជារឿងដែលអាម៉ាស់បំផុត។ លោកស្រីបញ្ជាក់ថា "ជីវិតរបស់ស្ត្រី និងខ្លួនរបស់ស្ត្រី គឺមានតម្លៃណាស់មិនអាចកាត់ថ្លៃបានទេ ហើយបើយកបណ្ណាការមកធ្វើខែល សម្រាប់លក់ដូរ វាគឺជារឿងមួយគួរឲ្យអាម៉ាស់ខ្លាំង ហើយវានឹងធ្វើឲ្យស្ត្រីហ្នឹង គាត់នៅទទួលរងដូចថា តួនាទីរបស់គាត់ត្រូវតែជាអ្នកផ្តល់សេវាសម្រាប់ប្តីដែលជាដៃគូរបស់គាត់"។

លោកស្រី សុភាព បន្តថា ការបង្គាប់ថ្លៃបណ្ណាការនេះគឺបានផ្ទុយនឹងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលត្រូវបានរដ្ឋសភាអនុម័តនាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ និងព្រឹទ្ធសភាអនុម័តនិងទទួលស្គាល់កាលពីថ្ងៃទី២៩ខែឆ្នាំដដែល ដែលបានចែងថាការរៀបអាពាហ៍ពិពាហ៍រវាងស្ត្រីនិងបុរស គឺធ្វើឡើងដោយគ្មានការបង្ខិតបង្ខំ ហើយជាការសម្រេចចិត្តដោយសាមីខ្លួនទាំងពីរ។ លោកស្រីបន្ថែមថា ការស់នៅចុះសម្រុងគ្នា មិនមែនទាល់តែការរៀបការនោះ ចំណាយអស់លុយរាប់លាននោះទេ។ លោកស្រី រស់ សុភាព ចាត់ទុកការទារថ្លៃបណ្ណាការទៅគ្រួសារខាងប្រុសច្រើនរបស់ឳពុកម្តាយខាងស្រី គឺជាលេសចង់បានមុខមាត់ខ្លួនគាត់តែប៉ុណ្ណោះ។

លោកស្រីបានបញ្ជាក់ថា "គាត់(ឳពុកម្តាយ)ក៏ត្រូវគិតដែរថា ពិធីការធំដុំនេះ តើទៅថ្ងៃអនាគតកូន បើសិនជាគាត់រៀបចំការហើយជំពាក់បំណុលគេ ឬមួយក៏កូនរស់នៅមិនចុះសម្រុងគ្នា តើមុខមាត់គាត់យ៉ាងម៉េច?"។

លោកស្រីសុភាពសំណូមពរឲ្យឳពុកម្តាយគ្រប់រូបគួរគិតឡើងវិញពីករណីនេះ។ ការធ្វើតាមទំនៀមទម្លាប់ដូនតា គឺមិនខុសទេ ក៏ប៉ុន្តែគួររៀបចំត្រឹមល្មមមួយសមរម្យជាជាងប្រឹងរៀបចំអធិកអធមថ្ងៃការ ហើយក្រោយរៀបការរួច កូនចៅត្រូវរកស៊ីដោះបំណុលថ្លៃចំណាយមង្គលការ។

ទាក់ទិនបញ្ហាថ្លៃបណ្ណាការនេះដែរ ឱជេ ណាណា ដែលត្រូវបានស្រទាបយុវវ័យ និងអ្នកវ័យកណ្តាលមួយចំនួនធំបានស្គាល់ថាជាអ្នកប្រឹក្សាយោបល់ដ៏មានប្រជាប្រិយមួយរូប ត្រូវបានកាសែតក្នុងស្រុកមួយស្រង់សម្តីថា ថ្លៃបណ្ណាការពិតជាមានសារៈសំខាន់ក៏ប៉ុន្តែវាមិនមែនសំខាន់សម្រាប់តែកូនស្រីនោះ ពោលគឺវាសំខាន់សម្រាប់ទាំងកូនស្រី និងកូនប្រុស។ តែយ៉ាងណាអ្នកប្រឹក្សាយោបល់រូបនេះ មិនគាំទ្រទេចំពោះការចំណាយលុយដ៏ច្រើនសម្រាប់ពិធីអាពាហ៍ពិពាហ៍នោះ ព្រោះកញ្ញាយល់ថា កិត្តិយសស្ត្រីមិនមែនទាល់តែបានថ្លៃបណ្ណាការច្រើន ឬក៏ការរៀបចំពិធីមង្គលការធំដុំនោះទេ។ កញ្ញាបានលើកឡើងថា "ខ្ញុំខ្លួនឯងក៏ជាមនុស្សស្រី ប៉ុន្តែខ្ញុំនឹងឆ្លើយថា កិត្តិយសរបស់ខ្ញុំមិនមែនបានមកពីបណ្ណាការច្រើនធ្វើពិធីបែបធំដុំទេ។ ខ្ញុំគិតថា កិត្តិយសរបស់ខ្ញុំបានមកពីអំពើល្អ បានមកពីភាពត្រឹមត្រូវ បានមកពីភាពជាសុភាពបុរស ឬក៏ការស្រឡាញ់ភរិយាពីមនុស្សដែលខ្ញុំអាចរៀបការជាមួយបានហៅថាស្វាមី។ ខ្ញុំគិតថា នោះទើបជាកិត្តិយសពិតប្រាកដ ក៏ប៉ុន្តែម្តងទៀត វាអាស្រ័យទៅនិយមន័យរបស់មនុស្សរៀងៗខ្លួន។ តែបើសួរខ្ញុំ ខ្ញុំគិតថាអត់ទេ"។

ដូចគ្នានិងអ្នកប្រឹក្សាយោបល់នេះដែរ កញ្ញា រស់ យុណណាងអាយុ២៤ឆ្នាំ ជាគ្រូបង្រៀនកម្រិតវិទ្យាល័យមួយរូប បាននិយាយថា សុភមង្គលរបស់ប្តីប្រពន្ធមិនអាស្រ័យទៅលើថ្លៃបណ្ណាការតិចឬច្រើនទេ តែវាអាស្រ័យទៅលើគូស្វាមីភរិយានោះស្រឡាញ់គ្នានិងយល់ចិត្តគ្នាប៉ុណ្ណោះ។ បន្ថែមពីនេះ កញ្ញាយុណណាង យល់ឃើញថា ការបង្គាប់ថ្លៃបណ្ណាការ ក៏មិនអាស្រ័យទៅលើកត្តាជីវភាពគ្រួសារខាងណានោះដែរ។ កញ្ញាបានលើកឡើងថា"យើងមើលទៅលើស្ថានភាពយើងដែរ មិនមែនថាគ្រួសារយើងក្រល្មមយើងទារបណ្ណាការគេខ្ពស់ ឬក៏មានយើងត្រូវទារគេឲ្យច្រើនក៏អត់ត្រូវតាមហ្នឹងដែរ"។

ជុំវិញទស្សនៈថ្លៃបណ្ណាការនេះ មជ្ឈដ្ឋានខ្លះ គឺចាំតែតាមដាននិងរិះគន់តែប៉ុណ្ណោះ ជាពិសេសអ្នកជិតខាង។ អ្នកខ្លះថា មូលហេតុដែលកូនស្រីទទួលបានបណ្ណាការតិចតួចពីខាងប្រុស ព្រោះតែស្ត្រីរូបនោះអាចមានទំនាក់ទំនងដល់រូបកាយ ទើបឳពុកម្តាយរបស់នាងយល់ព្រមលើកកូនស្រីឲ្យទាំងដែលទទួលបានថ្លៃបណ្ណាការទាប។

ត្រង់ចំណុចនេះ កញ្ញាយុណណាង មិនចាប់អារម្មណ៍លើពាក្យសម្តី នេះទេ ព្រោះនាងគិតថាគឺជារឿងសាមញ្ញទៅ ហើយដែលអ្នកជិតខាងតែងតែបេះបោចរឿងរ៉ាវរបស់អ្នកដទៃ។ តែចំណុចសំខាន់គឺមានតែសាមីដើមការប៉ុណ្ណោះ ដែលដឹងរឿងផ្ទៃក្នុង។

កញ្ញាបានបន្តថា "និយាយចំទៅ អ្នកជិតខាង តែយើងធ្វើទៅវាឃើញធំដុំគាត់ថាល្អហើយ តែយើងធ្វើមកតិចតួច គាត់មើលមកលក្ខណៈថាតាមតែមាត់គាត់និយាយ។ តែសំខាន់គឺសាមីខ្លួនពួកយើងទើបដឹងច្បាស់។ ហើយមួយទៀតមិនប្រាកដថា យើងយកបណ្ណាការគេមកច្រើន ធ្វើឲ្យអធិក ប៉ុន្តែលទ្ធផល គឺនៅខាងក្រោយពេលដែលយើងរៀបចំរួច។ យើងអត់គិតថា ត្រូវចំណាយអីៗផ្សេងហ្នឹង វានៅបានអី! ខ្ញុំគិតថា សំខាន់នៅពេលយើងរៀបចំមួយល្មមអីចឹងទៅ យើងរៀបការទៅសំខាន់ គឺអ្វីជាលទ្ធផលក្រោយយើងនៅជាមួយគ្នាទេ"។

យ៉ាងណាជុំវិញថ្លៃបណ្ណាការនេះ នារីម្នាក់ម្ចាស់គណនីហ្វេសប៊ុកមានឈ្មោះថា ម៉ា ធី បានសរសេរលើបណ្តាញសង្គមរបស់នាងថា មានមនុស្សជាច្រើនបានសួរនាងពីថ្លៃបណ្ណាការ ដែលនាងបានទទួលពីគូដណ្តឹងរបស់នាង ហើយពួកគេម្នាក់ៗ សុទ្ធតែបោះពាក្យសម្តីប្រហាក់ប្រហែលគ្នាថា ថ្លៃបណ្ណាការរបស់នាងហេតុអ្វីក៏បានតិចម្ល៉េះ។ លើសពីនេះអ្នកទាំងនោះ ចំអកថាថ្លៃបណ្ណាការរបស់នាងជាស្រីក្រមុំមិនស្មើនិងមេម៉ាយផង។ កញ្ញាបានបញ្ជាក់ថា "មិនតិចនាក់ទេ ដែលគេសួរខ្ញុំថា បង្គាប់បានប៉ុន្មាន? បាន១ម៉ឺនដុល្លារអត់? ម៉េចក៏ថោកម្ល៉េះ? យ៉ាប់ជាងគេមេម៉ាយទៀត។ គេមេម៉ាយសោះបានច្រើនជាងហ្នឹងផង"។

កញ្ញា ម៉ា ធី បន្តទៀតថា នាងមិនខឹងក៏មិនអន់ចិត្តអ្វីដែរ ចំពោះការចោទសួរដូច្នេះ។ ប៉ុន្តែស្ត្រីរូបនេះ សូមឲ្យមនុស្សគ្រប់គ្នាគិតជាថ្មីពីការបង្គាប់ថ្លៃបណ្ណាការច្រើនម៉ឺនដុល្លារ ទាំងដែលខ្លួនមិនមែនជាអ្នករកលុយនោះផង ហើយមិនតែប៉ុណ្ណោះតើអ្នកអាចយកលុយដែលគេខំរកយ៉ាងលំបាកមកចាយដោយស្រួលបានយ៉ាងដូចម្តេច៕




*ថតដោយៈ សម្បត្តិ*

*ដោយ សុផានិត*

# កម្មករនិងកម្មការិនី៖ ត្រូវតែទៅបោះឆ្នោតពីព្រោះនេះជាសិទ្ធិរបស់ពលរដ្ឋ

បណ្ដាកម្មករនិងកម្មការនីមួយ បាន អះអាងថា ពួកគេនឹងទៅបោះឆ្នោតនៅ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ដោយអះអាងថា នេះគឺជាសិទ្ធិរបស់ពួកគេហើយការទៅបោះឆ្នោតក៏មិនជាពិបាកអ្វីសម្រាប់ពួកគេដែរ ។

យុវកម្មការិនី សេត សុបច្ចានី ដែលមានវ័យ២៤ឆ្នាំកំពុងតែបម្រើការងារនៅរោងចក្រម្ដុំផ្លូវជាតិលេខ៤ម្ដុំអង្គស្នួលបានឲ្យដឹងថា វាដូចជាមិនមានអ្វីលំបាកទេនៅពេលដែលចេញទៅបោះឆ្នោតដោយសារតែនេះគឺជាពេលសម្រាក ហើយគ្រប់រោងចក្រនឹងឲ្យឈប់ហើយនៅថ្ងៃនោះ។

បច្ចនី បានអះអាងថា "ដូចអត់អីពិបាកអីសោះ គ្រាន់តែទៅមើលឃើញឈ្មោះ ហើយឈរតម្រង់ជួរកាន់តែកាត ហើយចូលទៅបោះទៅវាចប់ហើយ "។

កម្មការនីរូបនេះបានរៀបរាប់ថា មកដល់ពេលនេះកញ្ញាបានចូលរួមការបោះឆ្នោតប្រហែលជា២ដងហើយ គឺការបោះឆ្នោតកាលពីឆ្នាំ២០១៣ម្ដង និងការបោះឆ្នោត ក្រុមប្រឹក្សាឃុំ/សង្កាត់ម្ដងហើយ រាល់ពេលដែលកញ្ញាបានចូលរួម គឺមិនមានអ្វីលំបាកទេ គឺគ្រាន់តែប្រឡាក់ដៃ និង ឈររោងរោយជើងបន្តិច។

យុវតីរូបនោះ បានបញ្ជាក់ថា "បើតាមខ្ញុំចាំដូចជា បានចូលរួមការបោះឆ្នោតពីរដងហើយគឺនៅឆ្នាំ២០១៣ ម្ដង និង ដូចជាកាលពី ១ឆ្នាំមុនម្ដង"។

ទាក់ទិននឹងដំណើរការបោះឆ្នោតនេះដែរស្ត្រីជាកម្មការនីកាត់ដេរមួយរូបទៀតដែលកំពុងតែដើររករថយន្តដើម្បីត្រឡប់ទៅផ្ទះ ក្រោយពីបញ្ចប់ពីការងាររោងចក្រនៅតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញមួយរូបឈ្មោះជ័យ សុជាតិបានអះអាងថាឥឡូវគ្មានអ្វីពិបាកទេ សម្រាប់នាងនៅក្នុងការចេញទៅបោះឆ្នោត ដោយសារតែបច្ចុប្បន្នអ្នកនាងលែងស្នាក់នៅផ្ទះជួលទៀតហើយ ។

នៅក្នុងវ័យដែលសុជាតិ បានរៀបរាប់ថា មានអាយុជាង៣០ឆ្នាំ គឺបានចូលរួមការបោះឆ្នោតនោះ ៤ទៅ៥ដងដែរ ហើយកាលដែលលំបាកជាងគេ គឺការបោះឆ្នោត ពីរទៅបីដំបូងដែលនាងបានចូលរួម ដោយសារតែពេលនោះនៅផ្ទះជួល ហើយដើម្បីទៅបោះឆ្នោតបាន គឺត្រូវរៀបឥវ៉ាន់ ហើយរកឡានជិះទៅផ្ទះដើម្បីទៅយកឯកសារដើម្បីទៅបោះឆ្នោត ប៉ុន្តែឥឡូវមានស្អី បើអ្នកនាងលែងស្នាក់នៅផ្ទះជួលទៀតហើយ។ ព្រលឹមឡើងមានឡានគេមកដឹក ដល់ពេលចេញពីធ្វើការមានឡានមកដឹកត្រឡប់ទៅផ្ទះវិញ ដូច្នេះវាមិនមានអ្វីលំបាក ប្រញឹកប្រញាប់ដូចជា ការបោះឆ្នោតដំបូងដែលអ្នកនាងបានចូលរួមហើយនោះទេ ។

អ្នកនាងសុជាតិ បានអះអាងថា "ដូចកាលពីការបោះឆ្នោតឃុំប៉ុន្មានខែមុននេះមានទៅពិបាកស្អីដឹងតែពីងូតទឹកស្លៀកពាក់ចេញទៅតម្រង់ជួរបោះឆ្នោតតែម្ដង ពីព្រោះកន្លែងខ្ញុំបោះឆ្នោត កាលនោះគឺនៅសាលាក្បែរផ្ទះខ្ញុំហ្នឹង"។

យុវតីជាកម្មការនីម្នាក់ទៀត ដែលបានអះអាងប្រាប់ឈ្មោះថាស្រី ទិន អាយុ ១៩ឆ្នាំ បានអះអាង ទាំងអៀនប្រៀនថា នាងនឹងទៅបោះឆ្នោតនៅពេលខាងមុខ ដោយសារតែនេះគឺជាការបោះឆ្នោតលើកទីមួយរបស់កញ្ញា។

ស្រី ទិន បានអះអាងបញ្ជាក់ថា" មិនដឹងយ៉ាងម៉េចទេ តែខ្ញុំនឹងទៅបោះ។ ខ្ញុំចុះឈ្មោះរួចហើយ ហើយក៏មានអត្តសញ្ញាណបណ្ណរួចរាល់ហើយដែរ "។

ស្រីទិន បានអះអាងថា កញ្ញាមិនបានដឹងស្អីអំពីការបោះឆ្នោតនេះទេ ប៉ុន្តែកញ្ញាចង់ដឹងចង់ចូលរួម ពីព្រោះធ្លាប់តែឃើញគេទៅបោះ ពេលបោះឆ្នោតម្ដងៗ។

លោក សួន ប្រាជ្ញ ដែលជាអ្នកបើករថយន្តដឹកកម្មករដាក់ខែមួយរូប បាន អះអាងថា វាពិតជាគ្មានអ្វីលំបាកទេសម្រាប់កម្មករភាគច្រើន នាពេលបច្ចុប្បន្ននេះ ជាពិសេសគឺកម្មករនិងកម្មការនីដែលធ្វើការនៅតាមរោងចក្រម្ដុំផ្លូវជាតិលេខ៤ និងលេខ៣ ពីព្រោះភាគច្រើនពួកគេឈប់ស្នាក់នៅផ្ទះជួលហើយ។ ពួកគេភាគច្រើន គឺពួកគេស្នាក់នៅផ្ទះរបស់ពួកគេផ្ទាល់ ។

លោកបានបន្តថា កាលពីពេលបោះឆ្នោត ប្រហែលជាជាង១០ឆ្នាំមុនអី គឺលំបាកមែន ដោយសារតែពួកគេនៅផ្ទះជួល។ ដូច្នេះ ដើម្បីចេញទៅបោះឆ្នោតអ្នកខ្លះត្រូវរកឡានជិះទៅផ្ទះទាំងយប់ប្រសេចប្រសាចណាស់ តែឥឡូវអត់ទេភាគច្រើនកម្មករនិងកម្មការនីគេស្នាក់នៅផ្ទះគេ ហូបបាយនៅផ្ទះរបស់គេស្រាប់ៗ។

លោកបានបញ្ជាក់ថា "កម្មការនីឥឡូវនេះ រឿងទៅបោះឆ្នោតដូចជាមិនពិបាកទេ គ្រាន់តែភ្ញាក់ភ្លាមលុបតែមុខ ស្លៀកពាក់ទៅបោះតែហ្នឹងបានហើយ"។

លោកបានបន្តទៀតថា " ឥឡូវនេះស្រួលហើយបានប៉ុណ្ណឹង ពីមុន មិនមែនអីចឹងទេ កម្មការទៅបោះបានច្រើនតែពេលរសៀល ពីព្រោះវាពិបាករកឡានតាក់ស៊ីជិះមកផ្ទះពេលយប់។ តែឥឡូវខ្ញុំអី មានឡានដឹកអស់ហើយ។ ព្រឹកដឹកពួកគេទៅមួយជើងទៅ ដល់ល្ងាចដឹកពួកគេមកផ្ទះវិញមួយជើងទៀត។ ចឹងមានទៅពិបាកស្អី! សឹងតែនិយាយថាបើកតែភ្នែកទៅបោះឆ្នោតបាន"។

ទាក់ទិននឹងរឿងបោះឆ្នោតនេះសម្ដេចតេជោ ហ៊ុន សែន ដែលជាប្រធានគណបក្សកាន់អំណាច គឺ គណបក្សប្រជាជនកម្ពុជា តែងតែរំលឹករឿងបោះឆ្នោតនេះជាប្រចាំនៅលើបណ្ដាញសង្គមផ្លូវការផ្ទាល់ របស់សម្ដេច។ ជាក់ស្ដែងកាលពីថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៨ នេះ សម្ដេចក៏បានរំលឹករឿងនេះផងដែរ។

សម្ដេចតេជោ ហ៊ុន សែន បានរំលឹកថា ថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រគឺកាន់តែខិតជិតមកដល់ហើយគឺនៅតែជាង២ខែទៀតប៉ុណ្ណោះ! សូមក្មួយៗទៅបោះឆ្នោតទាំងអស់គ្នា។

គ.ជ.ប បានសម្រេចទទួលស្គាល់គណបក្សនយោបាយចំនួន ២០ឲ្យចូលរួមប្រកួតប្រជែង ក្នុងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨នេះ។



ថតដោយៈ កល្យប្រឹក្ស

# ពិធីអភិបូជាគោរពវិញ្ញាណក្ខន្ធលោកជីម នួណាន់ នៃក្រុមម៉ារីណុល



ថតដោយ: សុវណ្ណា

ពិធីរំលឹកវិញ្ញាណក្ខន្ធនេះ ប្រារព្ធឡើងក្រោម អធិបតីភាពរបស់លោកអភិបាល អូលីវីយេ ជ្មីតអឺស្លឺរ៉េ និងអភិបាលអន់តូនីសាមី ស្ទីសែរាជ្យ នាថ្ងៃទី០២ មិថុនា ២០១៨ នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូចរាជធានីភ្នំពេញ។

លោកបូជាចារ្យជីម នួណាន់ បានទទួលមរណភាពនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨ ក្នុងជន្មាយុ៨៣ឆ្នាំ។ លោកបំពេញបេសកកម្មនៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩៩១ រហូតដល់ ឆ្នាំ២០០៩។ នៅកម្ពុជា លោកបានបម្រើប្រជាជន និងបានចូលរួមស្តារព្រមទាំងអភិវឌ្ឍន៍ សង្គមកម្ពុជា ក្រោយរបបប្រល័យពូជសាសន៍ ប៉ុលពត ដោយសេចក្តីស្រឡាញ់។ ជិតពីរទសវត្សនៅកម្ពុជា លោកបានបង្កើតកម្មវិធីជាច្រើនដើម្បីជួយដល់អ្នកផ្ទុកមេរោគនិងជំងឺអេដស៍ ទាំងកុមារ និង មនុស្សពេញវ័យ ព្រមទាំងជួយលើកទឹកចិត្តពួកគេឲ្យមានក្តីសង្ឃឹមរហូតដល់ដង្ហើមចុងក្រោយ។ លោកបានបង្កើតកម្មវិធី ផ្សេងៗជាច្រើន ទៀតជាប្រយោជន៍ដល់ប្រជាជនកម្ពុជា។ ខាងក្រោមនេះជាយោបល់អស់បងប្អូនដែលស្គាល់លោក៖........



**លោកបូជាចារ្យ រ៉ូប៊ឺត ពិសេ** (ប៊ប់) ៖ ខ្ញុំស្គាល់លោកជីមតាំងពីឆ្នាំ១៩៧០នៅប្រទេសភីលីពីនដែលយើងបានជួបគ្នានៅទីនោះ និងខ្ញុំឃើញគាត់ជាមនុស្សសាមញ្ញធម្មតាមែនទែន។ គាត់មិនដែលមានឡាន មិនដែលមានម៉ូតូ គាត់ធ្លាប់តែជិះម៉ូតូឌុបតុកតុក ឡានក្រុងដោយមិនដែលមានឡានផ្ទាល់ខ្លួនឡើយ ហើយសម្លៀកបំពាក់គាត់ធម្មតា។ គាត់ជាមនុស្សមានរបៀបមិនស្មុគស្មាញទេ តែជាមនស្សស្រួលនិយាយ។ គាត់ចាប់អារម្មណ៍អំពីមនុស្សដែលមានសេចក្តីត្រូវការ តែងតែចង់ជួយគេដូចនៅទីនេះ នៅប្រទេសកម្ពុជាដោយជួយកូនកំព្រា និងជួយព្រមទាំងថែរក្សាមនុស្សដែលមានជំងឺអេដស៍ ទៅតាមសេចក្តីត្រូវការដែលលោកបានឃើញ។ ក្រៅពីសង្គមគាត់ក៏បានចូលរួមក្នុងសកម្មភាពព្រះសហគមន៍ជាច្រើនដែរ និងជាបូជាចារ្យដែលមានចិត្តសប្បុរស សាមញ្ញ និងមានជំនឿមាំមួន រស់នៅរបៀបត្រឹមត្រូវ និងជាសាក្សីពិតប្រាកដរបស់ព្រះជាម្ចាស់។



**បងស្រី រីជីណា** (ម៉ារីណុល)៖ លោកឪពុកជីមពីកាលអំឡុងឆ្នាំ១៩៨៧ ដែលជាពេលដែលពិបាកបំផុតនៅទីក្រុង គាត់មានបេសកកម្ម ដោយអត់ធ្មត់ជា-មួយអ្នកជំងឺទាំងឡាយដែលគ្មាននរណាជួយនិងថែរក្សា។ ខ្ញុំជឿថាទាំងលោកឪពុកជីម និងបងស្រីចយ(Joyce)បានចូលទៅក្នុងស្ថានបរមសុខដូចអ្វីដែលលោកឪពុកឆាលី និងលោកអភិបាលបានមានប្រសាសន៍នៅក្នុងអភិបូជា។ កាលដែលលោកឪពុកជីមនៅបំពេញបេសកកម្ម គាត់បានឃើញអ្វីដែលគាត់អាចធ្វើបាន គឺគាត់ធ្វើ។ ពួកយើងពិតនឹកគាត់!



**លោកយាយលីកេ៖** សម្រាប់ខ្ញុំលោកឪពុកជីម គឺមានគំនិតតែមួយក្នុងការចាប់ផ្តើមជួយសហគមន៍ជនជាតិវៀតណាមនៅពេលដែលមិនទាន់មានរដ្ឋាភិបាលមិនទាន់នរណាធ្វើកិច្ចការនេះ។ ពួកយើងបានចាប់ផ្តើម ដោយមានសាលាមត្តេយ្យដែលមានបួនសហគមន៍ផ្សេងៗគ្នា ហើយលោកឪពុកជីមបាននិយាយថា ប្រសិនបើមាននរណាម្នាក់គិតអំពីសហគមន៍នេះគឺពិតជាល្អ។ គាត់បានជំរុញយើង និងអ្វីដែលគាត់បានសន្ទនាគឺចេញមកក្នុងនាមជាបុត្រធីតារបស់ព្រះជាម្ចាស់។



លោក**វេជ្ជបណ្ឌិត គៀង វុទ្ធី** អតីតបុគ្គលិកម៉ារីណុល៖ លោកឪពុក ជីមតែងតែលើកទឹកចិត្ត និងជួយខ្ញុំឲ្យមានការតស៊ូ ព្រមទាំងធ្វើយ៉ាងណាឲ្យខ្ញុំមានការរីកចម្រើន ដោយឲ្យរៀនទាំងភាសា និងរៀនអំពីរបៀបទំនាក់ទំនងតាមម៉ែល(២០០១)។ អ្វីដែលខ្ញុំបានរីកចម្រើន និងអាចជួយប្រជាជនក្រីក្រជាច្រើនក៏ដោយសារតែបានការជម្រុញ និងលើកទឹកចិត្តពីគាត់។ រហូតមកដល់បច្ចុប្បន្ន ខ្ញុំនៅតែមានគំនិតជួយអ្នកក្រីក្រ និងមានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ ហើយគំនិតនេះត្រូវបានលោកឪពុកជីមបណ្តុះឲ្យខ្ញុំបន្តិចម្តងៗ។



**អ្នកស្រី ងួន ផល្លា** ជាបុគ្គលិកអង្គការម៉ារីណុល៖ ខ្ញុំធ្វើការជាមួយលោកឪពុកជីម ពីឆ្នាំ២០០២ រហូតដល់លោកវិលត្រលប់ទៅវិញ មិនដែលឃើញលោកខឹងបុគ្គលិកណា តែលោកលើកលែងទោសឲ្យគេជានិច្ចទាំងពាក្យសម្តី ទាំងកាយវិការ ហើយរបៀប ដែលគាត់ដោះស្រាយបញ្ហាគឺ មិនបានធ្វើឲ្យភាគីណា មានការឈឺចាប់នោះទេ។ ពេលខ្លះ ខ្ញុំឃើញអ្នកជំងឺវាយក្បាលលោក តែលោកមិនខឹងថែមទាំងអាណិតអាសូរគេ ទោះបីលោកឈឺក៏ដោយ។ លោកឪពុកជីម គឺជាគំរូដល់គ្រីស្តបរិស័ទ និងបុគ្គលិកគ្រប់រូប។ ខ្ញុំតែងតែអធិដ្ឋានសម្រាប់លោកជានិច្ច។



**បងប្រុស ធារី** ជាសមាជិកបព្វជិតក្នុងក្រុមម៉ារីស ដែលមានមករស់ប្រទេសកម្ពុជាយូរឆ្នាំហើយកំពុងបម្រើការងារនៅសាលាឡាវ៉ាឡា ជាមួយកុមារពិការ៖ ការចងចាំរបស់ខ្ញុំ អំពីលោកឪពុកជីម គឺមានច្រើនជាពិសេសណាស់ នៅក្នុងប្រទេសកម្ពុជា នៅក្នុងក្រុមគ្រួសារម៉ារីណុល។ គាត់ជាមនុស្សដែលមានយោបល់ល្អនៅក្នុងការងារសង្គមជាមួយបណ្តាញអង្គការឯទៀតៗ។ លោកឪពុកគឺជាថ្នាក់ដឹកនាំដ៏ល្អ។ នៅមានអនុស្សាវរីយ៍មួយទៀត គឺយើងជាមិត្តល្អនឹងគ្នា លោកឪពុកពូកែដោះស្រាយបញ្ហា។

# អាស៊ានអាចមានសមាជិកលើសពី១០

សព្វថ្ងៃនេះ អាស៊ានដែលគេដឹងថា គឺជាអង្គការអន្តរតំបន់មួយប្រមូលផ្តុំដោយ រដ្ឋចំនួន១០ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលគេស្គាល់ថា សមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍មានផ្ទៃដីសរុបប្រមាណជា ៤.៤៧៩.២១០គីឡូម៉ែត្រការ៉េ និងមាន ប្រជាជនប្រមាណជា ៦៤៣ លាននាក់ គឺអាចមានសមាជិកលើសពី១០ ។

រហូតមកដល់បច្ចុប្បន្ននេះ ប្រទេស សមាជិកទាំងស៊ានទាំង១០ គឺរួមមាន កម្ពុជា ឡាវ ភូមា វៀតណាម ហ្វីលីពិន ឥណ្ឌូនេស៊ី ប្រ៊ុយណេ ម៉ាឡេស៊ី ថៃ និង សិង្ហបុរី ប៉ុន្តែជាផ្លូវការគេដឹងថា មាន ប្រទេសពីរ កំពុងតែស្នើសុំជាសមាជិក អាស៊ាន ហើយបច្ចុប្បន្ននេះគឺកំពុងស្ថិត នៅក្នុងឋានៈជាប្រទេសសង្កេតការណ៍ នៅឡើយទេ។

ប្រទេសទាំងពីរនេះ ត្រូវបានគេដឹង ថា គឺប្រទេសប៉ាពួញូវហ្គេណេ និង ប្រទេសទីម័ខាងកើត។ ប្រទេសប៉ាពួញូវហ្គេណេដែលមានប្រជាពលរដ្ឋប្រមាណជា ៨ លាននាក់ និង មានផ្ទៃដី ៤៦២.៨៤០គីឡូម៉ែត្រការ៉េ។ ប្រទេនេះ គឺជាប្រទេសមួយ ដែលទទួលបានឯករាជ្យពីប្រទេសអូស្ត្រាលីនៅឆ្នាំ ១៩៤៩។ ប្រទេសនេះមានទីតាំងស្ថិតនៅក្នុងតំបន់ និរតីនៃមហាសមុទ្រប៉ាស៊ីហ្វិក ហើយ ភាគខាងជើងនៃប្រទេសអូស្ត្រាលី។

ដោយឡែកប្រទេសទីម័រខាងកើតត្រូវ បានគេដឹងថា គឺប្រទេសតូចមួយដែល ជាប់នឹងទីម័ខាងលិច នៅក្នុងប្រទេស ឥណ្ឌូនេស៊ី។ ប្រទេសទីម័ខាងកើត គឺជា អតីតដែនដីមួយរបស់ប្រទេសឥណ្ឌូនេស៊ី ដោយបានប្រកាសឯករាជ្យក្នុងឆ្នាំ ២០០២។ ប្រទេសនេះមានប្រជាពលរដ្ឋ ត្រឹមតែ១.១៦លាននាក់ និងជាប្រទេស ដែលមានភាសាព័ទុយហ្គាល់ជាភាសា ផ្លូវការ។

ក្នុងចំណោមប្រទេសសង្កេតការណ៍ អាស៊ានទាំងពីរនេះ ប្រទេសទីម័រខាងកើតជាប្រទេសដែលកំពុងតែខ្នះខ្នែងទាំង ការទូតនិងកិច្ចការផ្សេងៗ ដើម្បីទទួល សមាជិកភាពជាសមាជិកអាស៊ាន ហើយនៅក្នុងនោះ បណ្តាមេដឹកនាំអាស៊ានជាច្រើនក៏បានគាំទ្រ ជាពិសេសគឺ កម្ពុជា។ ប៉ុន្តែប្រទេសនេះនៅមិនទាន់ ដឹងថា តើពេលណាច្បាស់លាស់ទើបអាច ក្លាយជាសមាជិកអាស៊ានបានទេ ខណៈ ក៏មានព័ត៌មានថាមានប្រទេសមួយចំនួន បានទាមទារឲ្យប្រទេសនេះខិតខំបំពេញ លក្ខខណ្ឌផ្សេងៗមួយចំនួនបន្ថែមទៀត។

ក្រៅពីប្រទេសទាំងពីរ អូស្ត្រាលី ដែលគេដឹងថា គឺជាប្រទេសមួយនៅទ្វីប អូសេអានី ដែលនៅកណ្តាលមហាសមុទ្រ ដូចជាមានទំនោរនៅក្នុងការចូលរួមជា សមាជិករបស់អាស៊ានផងដែរ។ ថ្មីៗនេះ ព័ត៌មានបានផ្សព្វផ្សាយថា អូស្ត្រាលី ហាក់បង្ហាញជំហរ នៅក្នុងការក្លាយជា សមាជិកពេញសិទ្ធិនៅក្នុងអាស៊ាន។ ទាក់ទងនឹងទស្សនវិស័យនេះ លោកប្រធានាធិបតីឥណ្ឌូនេស៊ី ជូកូ វីដូដូ បានបង្ហាញ ជំហរគាំទ្របេក្ខភាពអូស្ត្រាលីឲ្យក្លាយជា សមាជិកអាស៊ានយ៉ាងពេញទំហឹងនិង ផ្លូវការនៅក្នុងជំនួបកំពូលរវាងមេដឹកនាំ អាស៊ានទាំង១០និងអូស្ត្រាលី។ ដោយ ឡែកលោកលី ស៊ានឡុង នាយករដ្ឋមន្ត្រី សិង្ហបុរី ក៏ដូចជាមានទំនោរគាំទ្រផង ដែរ។ នៅមុននេះវិទ្យាស្ថានយុទ្ធសាស្ត្រ នយោបាយអូស្ត្រាលីក៏បានត្រួសត្រាយនូវ ទស្សនវិស័យនយោបាយនេះផងដែរ។ តាមការគិតគូររបស់វិទ្យាស្ថាននេះ ទីក្រុង កង់បេរ៉ា (អូស្ត្រាលី) បានចេញរបាយការណ៍មួយថា អូស្ត្រាលីគួរស្វែងរកសមាជិកភាពអាស៊ាននៅក្នុងឆ្នាំ ២០២៤ ខាងមុខ ពោលគឺពេលនោះគឺជាខួប៥០ ឆ្នាំនៃទំនាក់ទំនងអូស្ត្រាលីនិងអាស៊ាន។

ទាក់ទងនឹងការចូលរួមរបស់អូស្ត្រាលី នេះ មតិមួយចំនួនបានស្វាគមន៍ដោយសារតែគេដឹងថា អូស្ត្រាលីគឺជាប្រទេស ដែលមានទាំងធនធានសេដ្ឋកិច្ច ក៏ដូច ជាធនធានមនុស្ស ដូច្នេះការចាប់ដៃគូរ រវាងអូស្ត្រាលី និង អាស៊ាន គឺជាឱកាស មួយដ៏ប្រពៃ សម្រាប់វឌ្ឍនភាពរវាងអាស៊ាននិងអូស្ត្រាលី។

និយាយអំពីអាស៊ាននីមួយៗ គឺមិន អាចមានសក្តានុពលដល់អូស្ត្រាលីទេ ប៉ុន្តែបើនិយាយអំពីអាស៊ានទាំងមូល គឺ ជាទីផ្សារដ៏មានតម្លៃមួយសម្រាប់អូស្ត្រាលី ហើយ ក៏មានទស្សនវិស័យថា ការទទួល អូស្ត្រាលី ឲ្យក្លាយជាសមាជិកអាស៊ានក៏ អាចនឹងពង្រឹងឥទ្ធិពលនយោបាយ និង យោធាមួយនៅក្នុងតំបន់ផងដែរ ដោយ សារតែ អូស្ត្រាលីក៏មានវិស័យការពារជាតិ ខ្លាំងមួយផងដែរ។ ដូច្នេះ ការចូលរួម របស់អូស្ត្រាលីក្នុងអាស៊ាន គឺអាចនឹង ពង្រឹងឥទ្ធិពលយោធា និងសេដ្ឋកិច្ច ប្រឆាំងនឹងប្រទេសនៅខាងក្រៅមួយចំនួន ជាពិសេសការកើនឡើងនូវឥទ្ធិពលរបស់ ចិននៅក្នុងតំបន់។ អាស៊ាននិងអូស្ត្រាលី គឺជាដៃគូរមួយដ៏មានសក្តានុពល ដោយ បច្ចុប្បន្ននេះ អាស៊ានមានអត្រាផលិតផលក្នុងស្រុកសរុបមិនអន់នោះទេ គឺ ៧.៩៣២ ទ្រីលានដុល្លារ ហើយប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅអាស៊ានវិញ ទោះបីជាមិនច្រើនដល់អូស្ត្រាលី ក៏គួរ សមដែរ គឺនៅក្នុងរង្វង់៤.២៩១ ដុល្លារ នៅក្នុងមួយឆ្នាំ។ ដោយឡែក មតិមួយ ទៀតបានលើកឡើងថា វាអាចជួបបញ្ហា ដោយសារតែអាស៊ានគឺអនុវត្តតាមគោលការណ៍កុងសង់ស៊ីស ដូច្នេះប្រសិនបេក្ខភាពរបស់អូស្ត្រាលីត្រូវបានប្រទេសមួយ ប្រានចោល គឺជាច់ខាតមិនបាននោះទេ ហើយនេះគឺជាចំណុចមួយ។ ម្យ៉ាងវិញ ទៀត បើនិយាយអំពីទីតាំងភូមិសាស្ត្រ គឺថា អូស្ត្រាលីមិនស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នោះទេ ខណៈដែលតំបន់នេះ ត្រូវបានកំណត់ទៅតាម ភូមិសាស្ត្រ នយោបាយមួយច្បាស់លាស់។

*ដោយអរិយបុត្រ*




ASEAN SECRETARIAT, FB

# ថតរូបក៏ជាអាជីពមួយដែលយុវជនគួរតែពិចារណា !




by Soun Sayon

*លេខនេះ អ្នកនាំសារសូមណែនាំមិត្តអ្នកអានឲ្យជួបជាមួយនឹងលោក សុវណ្ណ ភីឡុង ដែលជាអ្នកថតរូបអាជីពមួយរូប ។*

**អ្នកនាំសារ៖ *តើអាជីពជាអ្នកថតរូបរបស់លោកចាប់ផ្តើមតាំងពីណាមក?***

**លោក សុវណ្ណភីឡុង៖** ប្រហែលជា១០ឆ្នាំមុន នៅពេលនោះជាអ្វីដែលខ្ញុំមិនអាចបំភ្លេចបាន គឺនៅពេលដែលខ្ញុំចាប់ផ្តើមធ្វើការនៅក្នុងការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ដែលបានចំណាយពេលវេលាជាច្រើន នៅពេលដែលយើងគ្មានអីសោះ។ ពេលនោះ ខ្ញុំអត់ដឹងថាខ្ញុំអាចធ្វើអីបានក្រៅពីមានគំនិតមួយថាអាចបម្រើការងារណាក៏បាន ប៉ុន្តែដោយសារតែឆន្ទៈរបស់ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិកចង់ឲ្យមានការវិវឌ្ឍនល្អក្នុងវិស័យថតរូបនៅលើព្រឹត្តិបត្រសារព័ត៌មាន អីចឹងខាងការិយាល័យបានអញ្ជើញអ្នកអាជីពថតរូប ដែលមានលោក ម៉ក់ រ៉េមីសាមកបើកវគ្គបណ្តុះបណ្តាលខ្លី ហើយខ្ញុំក៏បានចូលរួមជាមួយនឹងបុគ្គលិតផ្សេងទៀតនៅទីនោះ។ ពេលនោះគឺតាមពិតខ្ញុំអត់ចូលចិត្តទេ ដោយសារខ្ញុំគិតថារូបថតហេតុអីយើងត្រូវការរៀន ដោយគ្រាន់តែមានកាម៉េរ៉ា ចាំបាច់អីទៅរៀននាំតែខាតពេល។ ជាក់ស្តែងនៅពេលនោះខ្ញុំកំពុងធ្វើការលើកម្មវិធីវីដេអូ ដែលថតវីដេអូនឹងកាត់តវីដេអូ។ ប៉ុន្តែអ្វីដែលបានផ្លាស់ប្តូរទាំងស្រុង គឺក្នុងរយៈពេលមួយម៉ោងដំបូង ក្រោយពីស្តាប់ការពន្យល់ពីស្អីគេជារូបថត តម្លៃនៃរូបភាព បានធ្វើឲ្យខ្ញុំផ្លាស់ប្តូរទាំងស្រុង ដូច្នេះខ្ញុំក៏សុំផ្តាំទៅថា ពេលខ្លះយើងមិនអាចមើលស្រាលទៅលើអ្វីដែលយើងមិនបានជួបប្រទះ ឬក៏យើងមិនទាន់បានគិតដល់។ ដូចសព្វថ្ងៃនេះ ខ្ញុំបន្តអាជីពនេះរហូតដល់ជាង១០ឆ្នាំ។ បើគិតទៅតាំងពី២០០៦ ដែលយើងចាប់ផ្តើមរៀនថតរូបរហូតដល់ពេលនេះគឺវា១២ឆ្នាំ។

**អ្នកនាំសារ៖ តើលោកមានទស្សនវិស័យផ្ទាល់ខ្លួនយ៉ាងណាចំពោះអាជីពថតរូបនេះ?**

**សុវណ្ណ ភីឡុង៖**សម្រាប់វិស័យថតរូបខ្ញុំគិតថាវាមានសារៈសំខាន់មែនទែននៅប្រទេសកម្ពុជាសព្វថ្ងៃ។ បើយើងក្រឡេកមើលទៅឃើញមានច្រើនទម្រង់ ដូចជាសារព័ត៌មាន នៅក្នុងផ្នែកផ្សេងៗដែលប្រជាជនខ្មែរពួកគាត់កំពុងតែចាប់យកមកប្រើប្រាស់ជាអាជីព ជាវិជ្ជាជីវៈមួយ។ អាចនិយាយបានថាវាជាអាជីពមួយច្បាស់លាស់ នៅពេលណាដែលគាត់ដឹងថាទំរង់នោះនៅក្នុងទិសដៅមួយណា។ បើសិនជាគាត់គិតថា ត្រឹមតែយកមកដើម្បីកម្សាន្តវាជារឿងមួយផ្សេងទៀត។ ដោយសារហេតុអីគ្រប់គ្នាតែងតែមានទិសដៅផ្សេងៗគ្នា។ ជួនកាលគាត់ចូលចិត្តដែរ ប៉ុន្តែគាត់មិនអាចចាប់ជាអាជីពបាន។ អ្នកខ្លះគឺគាត់បានផ្លាស់ប្តូរទាំងស្រុងដើម្បីចាប់យកជាអាជីពសម្រាប់គាត់រស់នៅ និងសម្រាប់ការងារ។ ដោយឡែកសម្រាប់ខ្ញុំកាលពីឆ្នាំ២០០៩ ខ្ញុំចង់ប្រឡូកក្នុងវិស័យរូបថតសារព័ត៌មាន។ ចន្លោះពីឆ្នាំ២០០៩ដល់ឆ្នាំ២០១១ ខ្ញុំបានផ្លាស់ប្តូរបន្តិច គឺទាក់ទងនឹងផ្នែកសិល្បៈ។ អីចឹងខ្ញុំថតរូបបែបសិល្បៈច្រើន តែផ្នែកនេះទាំងមូលអត់អាចជួយយើងទាំងស្រុងក្នុងជីវិតរស់នៅងាយស្រួលទេ។ ក្រៅពីការថតរូបបែបសិល្បៈ ខ្ញុំក៏ទទួលថតរូបបែបឯកសារ និងកម្មវិធីផ្សេងៗដូចគ្នា អ្វីដែលសំខាន់គឺយើងដឹងថា គោលដៅរបស់យើងនៅកន្លែងណា អីចឹងយើងអាចធ្វើការងារបន្ទាប់បន្សំបានជាច្រើនដើម្បីអោយសម្រេចនូវគោលដៅមួយដែលយើងត្រូវការសម្រាប់ខ្លួនឯង។

**អ្នកនាំសារ៖ នៅក្នុងអាជីពជាអ្នកថតរូប ទាំងសារព័ត៌មាន ទាំងសិល្បៈ តើមានផលលំបាកអ្វីខ្លះដែលលោកត្រូវប្រឈមមុខ ហើយលោកត្រូវដោះស្រាយដូចម្តេចខ្លះ?**

**សុវណ្ណ ភីឡុង:** ខ្ញុំនៅចាំបានថាពេលដែលនៅបម្រើការ នៅសារព័ត៌មាន បទពិសោធយើងបានទទួលជារៀងរាល់ថ្ងៃ ហើយពីមួយថ្ងៃទៅមួយថ្ងៃយើងជួបអ្វីដែលថ្មី។ពេលខ្ញុំចាប់ផ្តើមដំបូងគឺមានការលំបាកទាក់ទងជាមួយនឹងការទៅចូលរួមកម្មវិធីធំៗដែលគេមិនអនុញ្ញាត (ព្រោះ)គេមិនដែលស្គាល់យើងសោះ។ ហើយពេលខ្លះយើងពិបាកនៅក្នុងការសុំអនុញ្ញាត ទោះបីជាយើងមានប័ណ្ណសារព័ត៌មាន ឬប័ណ្ណសំគាល់កន្លែងការងារតែសួរថាយើងបោះបង់ចោលអត់ទេ? ទេ! គឺតែងតែជំនះដោយសារយើងគិតថា ដំណោះស្រាយវាមានពេលណាដែលយើងដាក់ចិត្តថាយើងចង់ធ្វើ។ ហើយខ្ញុំធ្លាប់ជួបជាមួយបញ្ហាធំៗច្រើន ចឹងគ្រប់ពេលដែលខ្ញុំប្រឈមមុខជាមួយបញ្ហាមួយគឺវាជួយយើង។ យើងអាចបត់បែនតាមកាលៈទេសៈ ឲ្យមានសុវត្ថិភាពសម្រាប់ខ្លួន ហើយបានរូបភាពដែលល្អសម្រាប់ស្ថាប័នរបស់យើង។ ជាទូទៅអ្នកខ្លះបានមើលគាត់មិនដឹងថា នៅពីក្រោយខ្នងរូបថតមួយសន្លឹកហ្នឹងតើអ្វីដែលកើតឡើង? ចឹងអ្វីដែលបានធ្វើអោយរូបភាពមួយនេះ ផ្តិតយកបានហើយអាចបង្ហាញបាន។

**អ្នកនាំសារ៖ តើអាចជម្រាបបានទេ តើលោកធ្លាប់ជួបបញ្ហាដែរឬទេនៅក្នុងអាជីពថតរូបរបស់លោក ?**

**សុវណ្ណ ភីឡុង៖** បាទខ្ញុំមានច្រើន ឧទាហរណ៍គេមានបាតុកម្មជាមួយអ្នកភូមិនៅបឹងកក់។ ចឹងខ្ញុំទៅថតពេលដែលគេប៉ះទង្គិចនឹងការរើផ្ទះ។ ចឹងពេលដែលកំពុងមានការប៉ះទង្គិចជាមួយអាជ្ញាធរ ប៉ូលីស ពេលនោះគាត់មានដកកាម៉េរ៉ា ពេលនោះមានការប៉ះទង្គិចខ្លះ ប៉ុន្តែខាងស្ថាប័នរបស់យើងគាត់ក៏បានទៅសម្របសម្រួល។ យើងបានទទួលកាម៉េរ៉ាមកវិញ តែខ្ញុំរងការប៉ះទង្គិចខ្លះទៅលើរាងកាយប៉ុន្តែការងារមួយនេះក៏បានរួមចំណែកឲ្យខ្ញុំទទួលបានពានរង្វាន់ផងដែរ។

**អ្នកនាំសារ៖ តើនៅក្នុងរយៈពេល១០ឆ្នាំមកនេះ លោកបានអភិវឌ្ឍខ្លួនយ៉ាងណា?**

**សុវណ្ណ ភីឡុង៖** សម្រាប់ខ្ញុំវាមានសារៈសំខាន់មែនទែន នៅពេលដែលខ្ញុំចាប់ផ្តើមវាដំបូង។ បើយើងក្រឡេកមើលនៅទីនេះ គឺយើងមានព័ត៌មានតិចតួចមែនទែនទាក់ទងជាមួយនឹងរូបថត ឬក៏សៀវភៅឯកសារផ្សេងៗ។ យើងនិយាយឲ្យចំទៅ យើងអត់មានសាលាត្រឹមត្រូវ ឬក៏សាលាដែលបង្រៀនឲ្យយើងក្លាយទៅជាអ្នកថតរូបអាជីព។ ដើម្បីឲ្យរីកចម្រើនបានយើងត្រូវបណ្តុះអ្នកជំនាន់ក្រោយឬក៏បង្ហាញផ្លូវដល់អ្នកដែលស្រលាញ់វិស័យថតរូបឲ្យចំទិស។ សម្រាប់ខ្ញុំមានសារៈសំខាន់មែនទែន ដែលអាចចែករំលែកបទពិសោធនៃវិស័យថតរូប ដោយសាររូបថតវាមានច្រើនដែលទូលំទូលាយមែនទែន។ ចឹងខ្ញុំអាចចែករំលែកបទពិសោធនេះ តាមរយៈការបង្រៀន ជាមួយអ្នកថតរូបផ្សេងទៀតជាអ្វីមួយដែលមានសារៈសំខាន់មែនទែន។ ហើយវានឹងធ្វើអោយវិស័យថតរូបនេះរីកចម្រើននៅក្នុងប្រទេសកម្ពុជា។ បើសិនជាយើងគិតថាចំណេះមួយនេះ យើងបានខំប្រឹងប្រែងដោយលំបាក ហើយមិនអាចចែករំលែកឲ្យគេបាន វាជារឿងអាត្មានិយមបន្តិច ព្រោះចំណេះមួយនេះ យើងត្រូវការរួមគ្នា។ បើសិនជាយើងចែករំលែកដល់អ្នកដទៃ ចឹងយើងគិតថាវិស័យថតរូបនេះនៅថ្ងៃណាមួយ វានឹងបានរីកធំធាត់ទូលំទូលាយ ឲ្យអន្តរជាតិឬក៏ស្ថាប័នផ្សេងទៀតទទួលស្គាល់ថា យើងក៏មានអ្នកថតរូបច្រើន ហើយបានបង្កើតស្នាដៃទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។ នេះហើយជាចំណុចសំខាន់សម្រាប់ខ្ញុំ។ ពេលណាដែលអ្នកថតរូបអាជីពគាត់បង្កើតស្នាដៃ គាត់បានចូលរួមគាំទ្រមែនទែន ហើយវាជាឱកាសសម្រាប់អ្នកដែលស្រលាញ់ការថតរូប ដែលចង់វិវឌ្ឍនខ្លួនឲ្យទៅជាអ្នកអាជីព។ *ដោយកល្យប្រឹក្ស*

# ពលរដ្ឋថា បើមិនទៅបោះឆ្នោតគឺជាការបំបាត់សិទ្ធិសេរីភា

ខណៈដែលដំណើរការបោះឆ្នោត នៅកម្ពុជាកំពុងតែវិវត្តន៍ទៅមុខ សង្គមក៏លេចចេញនូវយុទ្ធនាការផ្សព្វផ្សាយមួយថ្មីនេះ គឺចលនាតាមបណ្តាញសង្គមជំរុញមិនឲ្យពលរដ្ឋទៅចូលរួមបោះឆ្នោតនោះ ពលរដ្ឋមួយចំនួនបានអះអាងថា យុទ្ធនាការបែបនេះ គឺជាការជំរុញឲ្យពលរដ្ឋបំបាត់នូវសិទ្ធិ សេរីភាពខ្លួនឯង ។

ជុំវិញសកម្មភាពនិងយុទ្ធនាការបែបនោះពលរដ្ឋមួយចំនួននោះបានបញ្ចេញនូវទស្សនៈយោបល់ថា សូមប្រុងប្រយ័ត្ន ពីព្រោះ វាជាសកម្មភាពដែលអាចមានទោស ហើយបានស្នើរឲ្យមានការប្រុងប្រយ័ត្ន នៅក្នុងការធ្លាក់ខ្លួនជាអ្នកបម្រើយោបាយឲ្យគេ ដោយមិនបានដឹងអ្វីឲ្យស៊ីជម្រៅ។

លោក លឹម សម្បត្តិ ជាប្រជាពលរដ្ឋវ័យ ៤៣ឆ្នាំ មួយរូប បានឲ្យដឹងថា នាដំណាក់កាល ដែលការ បោះឆ្នោតកំពុងតែបោះជំហានមកដល់បន្តិចម្តងៗដូចជាបច្ចុប្បន្ននេះ សូមមានការប្រុងប្រយ័ត្នរឿងការធ្លាក់ខ្លួនឲ្យក្លាយជាឈ្នាន់នយោបាយរបស់គេ។

លោកបានបញ្ជាក់ថា "គេអ្នកនយោបាយហ្នឹង មិនចេះអីទេ តែយើងជាឈ្នាន់នយោបាយគេនេះ គឺត្រូវតែប្រយ័ត្នខ្លួន "។

តាមការរៀបរាប់របស់លោក សម្បត្តិ បានឲ្យដឹងថា អ្នកនយោបាយគឺគេរស់រវើកណាស់ ហើយគេបត់បែនវិញ ក៏លឿនណាស់ណាដែរ ដូច្នេះបើយើងតាមគេមិនទាន់ទេ គឺយើងអាចនឹងគ្រោះថ្នាក់ ដូចជាជាប់គុក គ្រោះថ្នាក់នេះ គ្រោះថ្នាក់នោះ...។

លោកបន្តទៀតថា មិនថាតែក្នុងប្រទេសទេ នៅទីណាក៏ដូចជាទីណាដែរមើលនៅថៃ នៅប្រទេសម៉ាឡេស៊ី ហ្វីលីពិនជាដើម ឲ្យតែពេលបោះឆ្នោត មកដល់ពលរដ្ឋសាមញ្ញាគឺអាចនឹងរងគ្រោះ ដោយសារតែ ការក្លាយខ្លួនជាឈ្នាន់នយោបាយរបស់គេ ។



*ពិធីចាប់លេខរៀងនៅលើសន្លឹកឆ្នោត នៃគណបក្សនយោបាយទាំង២០ ដែលចូលរួមប្រកួតប្រជែងក្នុងការ*

លោកបានបញ្ជាក់ទៀតថា "យើងជាពលរដ្ឋបានត្រឹមតែតាមដាន និងសំដែងមតិតាមឆន្ទៈរបស់ យើងពេលបោះឆ្នោតគឺជារឿងត្រឹមត្រូវបំផុត"។

អាជីវករវ័យប្រមាណជាក្រោម ៤០ឆ្នាំ មួយរូបបានឲ្យដឹងថា លោកមិនចង់ពាក់ព័ន្ធនឹងរឿង នយោបាយនោះទេ ។

លោក បានឲ្យដឹងដោយខ្លីថា អ្នករកស៊ីគ្រាន់តែដឹងៗ (អំពីនយោបាយ)ទៅបានហើយ មិនបាច់ស៊ី ជម្រៅ ដូចគេទេ ។

លោកបានបញ្ជាក់ថា "ខ្ញុំអ្នករកស៊ីមិនចង់ពាក់ព័ន្ធស្អីទេ រឿងនយោបាយ គឺជារឿងអ្នកនយោបាយ ខ្ញុំដឹងតែដល់ពេលខ្ញុំទៅបោះឆ្នោតទៅបានហើយ"។

លោក សែម សុបញ្ញា ជាប្រជាពលរដ្ឋមួយវ័យ ៣៩ឆ្នាំ បានឲ្យដឹងថា អ្នកនយោបាយគេធ្វើ នយោបាយ គេអត់មានបញ្ហាអីទេ ដោយសារតែគេដឹងក្តៅត្រជាក់ តែយើងជាជនសាមញ្ញ ដែលអត់ដឹងអី សោះ ចង់ទៅពាក់ព័ន្ធជាមួយគេ ចង់ទៅបម្រើនយោបាយនឹងគេសូមប្រុងប្រយ័ត្ន។ លោកបានបន្ត ទៀតថា ច្បាប់ឥឡូវនេះមានច្រើនណាស់ យើងជាពលរដ្ឋសាមញ្ញកម្រចេះច្បាប់អស់ណាស់ ដូច្នេះ ពេលដែលយើងចូលរួម ឬសម្តែងនូវទស្សនៈមួយ នៅក្នុងន័យសំដែងឆន្ទៈរបស់យើងផ្ទាល់ យើងក៏អាចនឹងមានទោសដែរ។

លោក សុបញ្ញា បានផ្តាំផ្ញើថា " បើយើងមិនមែនអ្នកនយោបាយកុំចង់មកលេងហ្គេមហ្នឹងប្រយ័ត្ន។គេអ្នកនយោបាយមិនអីទេ តែយើងត្រូវរកស៊ីចិញ្ចឹមប្រពន្ធកូន ពេលមានរឿង មានទុក្ខមានទោស បានអ្នកណាចិញ្ចឹមកូន មើលថែទាំងប្រពន្ធទៅ"។

លោកបានបន្តទៀតថា ច្បាប់ឥឡូវមានច្រើនណាស់ តែយើងមិនប្រយ័ត្ន ធ្លាក់នៅក្នុងការអូសទាញ របស់អ្នកនយោបាយ យើងអាចមានទុក្ខទោសនឹងគេ ពីព្រោះថាអ្វីៗទាំងអស់គឺត្រូវតែស្ថិតនៅក្នុងច្បាប់។ លោកបានបន្តទៀតថា យើងមានសិទ្ធិ យើងមានភារកិច្ច យើងមានកាតព្វកិច្ចសម្តែង

## គណបក្សចូលរួមការបោះឆ្នោតនៅថ្ងៃទី ២៩ ខែ កក្កដា មាន ២០

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២៩ ខែ ឧសភាបានរៀបចំកំណត់ លំដាប់លេខរៀងគណបក្សនៅលើសន្លឹកបោះឆ្នោតរួចរាល់ហើយ ដោយសម្តេចសង្ឃរាជទាំង២គណបក្សជាអ្នកចាប់ ដោយពិធីនេះមានការចូលរួមដោយអ្នកការទូត អ្នកជំនាញការបរទេស មន្ត្រីគណបក្សនយោបាយទាំង២០ និងអ្នកសារព័តមានជាតិនិងអន្តរជាតិ ។

នៅលើសន្លឹកឆ្នោត លេខរៀងទី១គឺគណបក្សខ្មែររួបរួមជាតិ, ទី២គណបក្សមាតុភូមិយើង, ទី៣គណបក្សពន្លឺថ្មី, ទី៤គណបក្សសញ្ជាតិកម្ពុជា, ទី៥គណបក្សខ្មែរក្រោក, ទី៦គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ, ទី៧គណបក្សប្រជាធិបតេយ្យមូលដ្ឋាន, ទី៨គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ, ទី៩គណបក្សរស្មីខេមរា, ទី១០គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ, ទី១១គណបក្សខ្មែរសាធារណរដ្ឋ, ទី១២គណបក្សខ្មែរឈប់ក្រ, ទី១៣គណបក្សហ៊្វុនស៊ិនប៉ិច, ទី១៤គណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច, ទី១៥គណបក្សយុវជនកម្ពុជា, ទី១៦គណបក្សធម្មាធិបតេយ្យ, ទី១៧គណបក្សឆន្ទៈខ្មែរ, ទី១៨គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា, ទី១៩ គណបក្សខ្មែរតែមួយ និងទី២០គណបក្សប្រជាជនកម្ពុជា។

# ពខ្លួនឯង



ោះជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ ។ ថតដោយៈ ឡុង សម្ផស្ស

ឆន្ទៈនយោបាយរបស់យើង ប៉ុន្តែកុំភ្លេចថា សិទ្ធិទាំងអស់គឺត្រូវតែស្ថិតនៅក្នុងដែនកំណត់នៃច្បាប់។

ទាក់ទិននឹងយុទ្ធនាការក៏ដូចជាសកម្មភាពដែលមានបុគ្គលមួយចំនួនកំពុងតែចែករំលែក និងផ្សព្វផ្សាយនូវខ្លឹមសារថា ខ្លួនមិនទៅបោះឆ្នោតតាមបណ្តាញសង្គម ជាពិសេសគឺហ្វេសបុកនោះ លោក លឹម សម្បត្តិ បានឲ្យដឹងថា នេះអាចជាសិទ្ធិរបស់គេ ប៉ុន្តែតាមព័ត៌មានឮថា ខាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួងមហាផ្ទៃកំពុងតែសិក្សាអំពីវិធានការណ៍ផ្លូវច្បាប់ហើយ។

លោក បញ្ជាក់ថា "មិនដឹងករណីនេះដែរ តែខ្ញុំថា តែគេហ៊ានធ្វើបែបនេះគេហ៊ានទទួលខុសត្រូវហើយ ប៉ុន្តែអាណិតៗចំពោះអ្នកដែលអត់ដឹងអីសោះ ទៅធ្វើតាមគេដោយមិនដឹង ខ្យល់ អីនោះ"។

គួររំលឹកដែរថា ថ្មីៗនេះក្រុមអ្នកនយោបាយមួយចំនួន ដែលកំពុងតែនិរទេសខ្លួននៅក្រៅប្រទេស ក្រោយពេលដែលគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងត្រូវបានតុលាការកំពូល ប្រកាសសាលដីការំលាយគណបក្សចោល ដោយសារតែការចោទប្រកាន់នឹងករណីគប់គិតបរទេសកំពុងតែធ្វើយុទ្ធនាការ និងចលនាមិនឲ្យប្រជាពលរដ្ឋទៅបោះឆ្នោត។

លោកសម រង្ស៊ី ដែលជាអតីតប្រធានគណបក្សនេះ ហើយបានកំពុងតែរស់នៅនិរទេសខ្លួនពីបណ្តឹងរបស់អាជ្ញាធរមានសមត្ថកិច្ច និងសាលក្រមជាច្រើនករណីពីស្ថាប័នតុលាការកម្ពុជាកំពុងតែធ្វើយុទ្ធនាការនេះយ៉ាងផុលផុសនៅលើបណ្តាញសង្គម ជាពិសេសគឺហ្វេសបុក។

លោក សម រង្ស៊ី បានផ្សព្វផ្សាយថា "ពលរដ្ឋម្នាក់ៗ មានសិទ្ធិមានយោបល់ថា ការបោះឆ្នោតថ្ងៃ២៩ កក្កដា ខាងមុខ មិនមែនជាការបោះឆ្នោតមែនទែនទេ គឺជាការបោះឆ្នោតក្លែងក្លាយ ពីព្រោះពលរដ្ឋ យ៉ាងតិចពាក់កណ្តាលនគរ ដែលស្រលាញ់និងគាំទ្រគណបក្សសង្គ្រោះជាតិ តាំងពីឆ្នាំ ២០១៣ មក មិន អាចជ្រើសរើសគណបក្សនេះបានទេ ដោយសារតែមិនមានឈ្មោះគណបក្សនេះ លើសន្លឹក ឆ្នោតឡើយ..." ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានហៅយុទ្ធនាការរបស់លោក សម រង្ស៊ី និងក្រុមសកម្មជនរបស់លោកថា គឺជាសកម្មភាពខុសច្បាប់ខណៈដែលពេលនេះ ដំណើរការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនីតិកាលទី ៦ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៨នេះ កំពុងតែរៀបចំដោយរលូន និងមានគណបក្សចូលរួមប្រកួត ប្រជែងរហូតដល់ទៅ ២០ គណបក្ស ។

ទាក់ទិននឹងយុទ្ធនាការរបស់ក្រុមអ្នកនយោបាយទាំងនេះ លោក ស៊ិក ប៊ុនហុក ប្រធានគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតថ្មីៗនេះបានដាក់លិខិតស្នើសុំឲ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានវិធានការផ្លូវច្បាប់ចំពោះការអំពាវនាវឲ្យប្រជាពលរដ្ឋធ្វើពហិការក្នុងការបោះឆ្នោត នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨។

លោក ហង្ស ពុទ្ធា អ្នកនាំពាក្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានថ្លែងបញ្ជាក់នៅក្នុងសន្និសីទកាសែតកាលពីព្រឹកថ្ងៃទី១៧ ខែឧសភា ថា ការឃោសនាមិនឲ្យប្រជាពលរដ្ឋទៅបោះឆ្នោតគឺជាការឃោសនាតាមរបៀបបំបែកបំបាក់ជាតិ។

លោកបានមានប្រសាសន៍ថា នេះគឺជា ទង្វើផ្ទុយច្បាប់ដើរប្រាសជាមួយនឹងច្បាប់ ដើរប្រាសជាមួយចរន្តសង្គមដែលគណបក្សនយោបាយចំនួន២០ជឿជាក់លើការបោះឆ្នោត និងបានចុះឈ្មោះហើយប្រជាពលរដ្ឋជាង៨០ភាគរយបានត្រៀមលក្ខណៈនៅក្នុងការបោះឆ្នោតនេះ គឺជាភាពផ្តាច់មុខមួយដែលមិនមែនជាធាតុពិតនៃលទ្ធិប្រជាធិបតេយ្យដែលសកលលោកចង់បាននោះទេ។

លោកបានមានប្រសាសន៍បញ្ជាក់ទៀតថា លទ្ធិប្រជាធិបតេយ្យគឺ មិនមានភាពផ្តាច់មុខ ខាងគណបក្សនយោបាយណាមួយទេ។

លោកបានបន្តថា ក្រសួងមហាផ្ទៃ និង គ.ជ.ប កំពុងតែសិក្សាផ្លូវច្បាប់ហើយ ក៏ចង់ទប់ស្កាត់ឲ្យមានប្រសិទ្ធភាពដែរ។ ប៉ុន្តែ គ.ជ.ប មិនចង់ឲ្យមានការដាក់ទោសទណ្ឌដល់អ្នកនេះដល់អ្នកនោះ ពីព្រោះតែរឿងបោះឆ្នោតទេ។

លោកបានមានប្រសាសន៍បន្តទៀត ថា គ.ជ.ប មានបេះដូងទូលាយ ប៉ុន្តែអ្វីដែលធ្វើឡើង ដោយមធ្យោបាយទុច្ចរិតផ្សេងៗ គ.ជ.ប ក៏ត្រូវតែមានការចាត់ចែងរៀបចំហើយអនុវត្តឲ្យបានត្រឹមត្រូវផងដែរ។

ជុំវិញបញ្ហានេះ សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានមានប្រសាសន៍នៅក្នុងកិច្ចប្រជុំស្តីពីលទ្ធផលការពារ និង ការត្រៀមលក្ខណៈសម្បត្តិដើម្បី ការពារសុវត្ថិភាពដំណើរការបោះឆ្នោតកាលពីព្រឹកថ្ងៃទី២៨ ខែឧសភា ថា អ្នកដែលរារាំងប្រជាពល - រដ្ឋមិនឲ្យទៅបោះឆ្នោត គឺមានកំហុសហើយ ច្បាប់បានចែងច្បាស់ ប៉ុន្តែការសម្រេចទៅបោះឆ្នោត ឬមិនទៅជាសិទ្ធិរបស់ប្រជាពលរដ្ឋ នេះបើតាមរដ្ឋធម្មនុញ្ញនិងច្បាប់បោះឆ្នោត។

សម្តេចបានបន្តថា ចំពោះអ្នករារាំង បើសិនណាអាជ្ញាធរឃើញថាមានការរារាំងមានភស្តុតាង ដាក់ស្តែងត្រូវតែទទួលទោស។

សូមរំលឹកជាថ្មីថា ការបោះឆ្នោតជ្រើសរើស តំណាងរាស្ត្រនីតិកាលទី ៦ នឹងប្រព្រឹត្តទៅនៅ ថ្ងៃ អាទិត្យ ទី ២៩ ខែ កក្កដា ឆ្នាំ ២០១៨។

ការបោះឆ្នោតនេះ មានការចូលរួម ពីគណបក្សទាំងអស់ ២០ ខណៈដែលកាលពីអាណត្តិមុនមានតែ ៨ គណបក្ស ប៉ុណ្ណោះបានចូលរួម។

## គ.ជប.ថាពលរដ្ឋបោះឆ្នោត៨,៣៨ លាននាក់មានសិទ្ធិបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)បានប្រកាសថា កម្ពុជាមានពលរដ្ឋដែលមានសិទ្ធិស្របច្បាប់ដើម្បីចូលរួមបោះឆ្នោតសរុបចំនួន ៨,៣៨ លាននាក់ ដែលពួកគេនឹងអាចមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតចំនួន ២២.៩៦៧ ស្ថានីយ៍បោះឆ្នោត។

ប្រភពដដែលបានអះអាងកាលពីថ្ងៃទី២៣ខែឧសភាថាអ្នកសារព័ត៌មានជាតិនិងអន្តរជាតិចំនួន២៨៤នាក់មកពីអង្គភាពសារព័ត៌មានចំនួន៣៥ ត្រូវបានទទួលស្គាល់ ដើម្បីចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត ហើយក្រៅពីនេះនៅមានអ្នកសារព័ត៌មានចំនួន១៩៦នាក់ផ្សេងទៀតកំពុងពិនិត្យ។

ប្រភពដដែលបានបន្តថា ចំនួនអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិនៃសមាគមអង្គការមិនមែនរដ្ឋាភិបាលចំនួន២១៧៨នាក់ ត្រូវបានគ.ជ.បអនុញ្ញាតឲ្យចូលរួមសង្កេតមើលការបោះឆ្នោតរួចហើយ កាលពីថ្ងៃទី១៧ខែឧសភា ហើយអ្នកសង្កេតការណ៍ជាតិ១.៥៥៥នាក់និងអន្តរជាតិ៣នាក់ផ្សេងទៀត គ.ជ.បកំពុងពិនិត្យ៕

# ឡូនលីទ្រីកាហ្វេ ផ្ដល់ការងារដល់នារីពិការ




ថតដោយ សុវណ្ណា

អង្គុយនៅលើរទេះរុញក្នុងភោជនីយដ្ឋានជាន់ផ្ទាល់ដី ដែលផ្ទុកដោយខោអាវព្យួររណោងរណោង និងមានគ្រឿងលង្ការមួយចំនួនរៀបយ៉ាងមានរបៀបរៀបរយ នារីពិការ ជើងទាំងសងខាងទទួលស្វាគមន៍ភ្ញៀវដោយរាក់ទាក់និងញញឹមផង។ រឿន សៃហ្វុងបានរៀបរាប់ថា "នៅនេះ យើងអាចទទួលបទពិសោធន៍ថ្មីៗ ព្រោះពីមុនហ្នឹង ខ្ញុំអត់មកធ្វើការនៅនេះ ខ្ញុំអត់សូវចេះធ្វើអីទេ។ ឧទាហរណ៍ ការនិយាយជាមួយភ្ញៀវអីចឹង។ ខ្ញុំអត់ចេះធ្វើអីមួយអីចឹង មេរបស់ខ្ញុំគាត់បង្រៀន"។

និយាយបណ្ដើរឆ្លើយតបនឹងភ្ញៀវទិញសំលៀកបំពាក់របស់ខ្លួនបណ្ដើរ នារីពិការរូបនេះបាននិយាយថា ទោះបីជានាងពិការជិះលើរទេះរុញ ក៏នាងនៅតែអាចធ្វើការងារបានតាមលទ្ធភាព និងសមត្ថភាពរបស់នាង ដែលជាការអនុគ្រោះពីកន្លែងធ្វើការ។ សៃហ្វុង "ប៉ូវីយ៉ូ។ ខ្ញុំដើរបានតិចៗ តែដើរឆ្ងាយអត់បាន។ ប្រសិនបើមានអីទប់ ខ្ញុំអាចដើរបាន។ ជិះរទេះរុញ (ការងារលក់)ខ្ញុំអាចធ្វើបានតើ"។

រឿន សៃហ្វុង ពេលនេះអាយុ២៧ឆ្នាំ ដែលកំពុងធ្វើការងារនៅក្នុងហាងមួយឈ្មោះឡូនលីទ្រីកាហ្វេ ដែលជាអាហារដ្ឋានមួយនៃគម្រោងសហគ្រិនសង្គម របស់ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ដែលស្ថិតនៅកំណាត់ផ្លូវលេខ២កន្លះ ក្នុងក្រុងបាត់ដំបង។ សៃហ្វុងបានមកធ្វើការងារនៅទីនោះបានជាង៤ឆ្នាំមកហើយ។ នាងជាអតីតសិស្សទទួលអាហារូបករណ៍ពីមណ្ឌលអរ៉ូពេ ដែលជាកន្លែងទទួលកុមារពិការឲ្យស្នាក់នៅនឹងរៀនសូត្រ។ យុវតីជដែលនេះរំលឹកថា នាងបានទទួលជីវិតបែបនេះ ដោយសារតែលោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង អេនរីគេ ហ្វីការេដូ ដែលបានទទួលនាងដើម្បីឲ្យបានទទួលការសិក្សារៀនសូត្រតាំងតែពីនាងនៅវ័យកុមារ។ សៃហ្វុង "ពេលដែលខ្ញុំស្គាល់គាត់ ខ្ញុំអាចចូលសាលារៀនបាន ខ្ញុំអាចស្គាល់អ្វីខាងក្រៅ(សង្គម)ម៉េចៗអីចឹង។ ពីមុនខ្ញុំជាអ្នករាំរបាំនៅក្នុងអរ៉ូពេ។ ខ្ញុំអាចរាំបាន ខ្ញុំអាចមានលទ្ធភាពចេញទៅក្រៅប្រទេស។ ខ្ញុំអាចធ្វើការនៅនេះ ខ្ញុំអាចរៀនអង់គ្លេស ខ្ញុំអាចបញ្ចប់ថ្នាក់ទី១២"។

នៅជាន់ទី១នៃអាហារដ្ឋានមានកន្លែងទទួលភ្ញៀវដែលមានរៀបចំតាមបែបទំនើបនិងសាមញ្ញ មានតុ និងកន្លែងអង្គុយទទួលទានអាហារ។ យុវនារី៣នាក់កំពុងទទួលភ្ញៀវដែលបានមកទទួលទានអាហារនៅទីនោះ។ និយាយភាសាអង់គ្លេសបន្តិចបន្តួចប្រកបដោយស្នាមញញឹមយ៉ាងរួសរាយរាក់ទាក់ យុវនារីឈ្មោះរិទ្ធ សំ អាយុ២៩ឆ្នាំ បាននិយាយថា"ធ្វើការនៅនេះ និយាយទៅមានអារម្មណ៍ថាសប្បាយដែរ ណាមួយជិតផ្ទះ ណាមួយយើងធ្លាប់នៅមណ្ឌល លោកពុកធ្លាប់ជួយមករហូត ហើយធ្វើការនៅនេះ យើងសប្បាយដែរ។ ខ្ញុំស្គាល់ភ្ញៀវច្រើនមកពីគ្រប់ប្រទេសហើយខ្ញុំបានអនុវត្តភាសាអង់គ្លេសខ្ញុំដែរ ដោយសារខ្ញុំអត់សូវចេះនិយាយអង់គ្លេសទេ"។

យុវនារី រិទ្ធ សំ បានធ្លាក់ខ្លួនពិការតាំងពីអាយុ៩ឆ្នាំដោយសារគ្រាប់មីន ពេលនាងទៅចំការដើម្បីធ្វើការងារស៊ីឈ្នួលឲ្យគេ។ អង្គុយនៅតុអាហារ បន្ទាប់ពីស្បើយភ្ញៀវបន្តិច សំបានបន្តទៀតថា ក្រុមការងាររបស់លោកអភិបាលភូមិភាគបាត់ដំបងនាំនាងពីភូមិ ឲ្យមករស់នៅនិងរៀនសូត្រនៅក្នុងមណ្ឌលកុមារពិការឈ្មោះអរ៉ូពេយូរឆ្នាំហើយ ហើយលោកអភិបាលបានផ្ដល់ការងារធ្វើនៅក្នុងហាងមួយនេះ ប្រមាណជិត៤ឆ្នាំមកហើយ បន្ទាប់ពីនាងបានរៀនចប់ទៀត គឺបានផ្ដល់នូវក្ដីសង្ឃឹមថ្មីសម្រាប់ជីវិតរបស់នាងនិងឲ្យនាងអាចចូលរួមនៅក្នុងសង្គមបាន។ រិទ្ធ សំ "មានអារម្មណ៍ថាតក់ស្លុតខ្លាំងណាស់! ហើយគិតថាប្រហែលមិនអាចមានជីវិតរស់នៅទេ។ ជាពិសេស ខ្ញុំស្រឡាញ់ដៃខ្ញុំ ព្រោះដៃខ្ញុំធ្លាប់សរសេរអក្សរ ដល់ពេលឃើញអីចឹងទៅតក់ស្លុតមែនទែន! ត្រូវកន្លែងផ្សេងទៀតអត់ខ្វល់ទេ តែឃើញម្រាមដៃអីចឹងតក់ស្លុត។ ហើយចាប់ពីពេលហ្នឹងមកខ្ញុំដូចពិបាកដែរ។ ដូចថាយើងធ្លាប់រៀនពូកែចឹង ក្រោយមកអត់សូវទទួលបាន។ ហើយទឹកចិត្តពេលខ្លះវាបាក់តិចៗដែរ ដោយសារយើងវាពិបាកដើរ យើងពិបាកចូលចំណោមគេ។ តែពេលយើងមកនៅមណ្ឌល យើងឃើញគេពិការច្រើនហើយម្យ៉ាងទៀតខ្ញុំមានការងារធ្វើហើយការបាក់ទឹកចិត្តបានកាត់បន្ថយ ការសប្បាយបានកើនឡើងខ្លះៗ"។

ឡូនលីទ្រីកាហ្វេ ជាហាងលក់វត្ថុអនុស្សាវរីយ៍ និងជាអាហារដ្ឋាន បង្កើតឡើងក្នុងឆ្នាំ២០១៣ ដោយលោកអភិបាលអេនរីគេ ហ្វីការេដូស្ថិតនៅក្នុងគម្រោងនៃសហគ្រិនសង្គមរបស់ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ដោយមានជំនួយពីអង្គការសាវអូសេពីអេស្ប៉ាញ និងអង្គការកាតូលិកបេសកកម្មអូស្ត្រាលីក្នុងទិសដៅបង្កើតការងារដល់យុវជននារី និងស្វែងរកប្រាក់ចំណេញដើម្បីជួយដល់សកម្មភាពមនុស្សធម៌ក្នុងភូមិភាគ។

លោកអភិបាលអេនរីគេ ហ្វីការេដូ ជាស្ថាបនិកបានមានប្រសាសន៍អំពីគោលបំណងនៃការបង្កើតអាហារដ្ឋាននេះថា នៅក្នុងឡូនលីទ្រីកាហ្វេនេះ គឺមានទិសដៅបីសំខាន់ៗគឺដើម្បីរកទីផ្សារសម្រាប់សិប្បកម្មរបស់ព្រះសហគមន៍ និងចង់បង្ហាញថា ជនពិការមានសមត្ថភាពច្រើនក្នុងបំពេញការងារ។ មួយទៀតដើម្បីអប់រំដល់យុវជនយុវនារីដែលធ្វើការងារនៅក្នុងហាង រៀនអំពីរបៀបនៃការទំនាក់ទំនងជាមួយសង្គម។ មួយទៀតគឺដើម្បីរកប្រាក់ចំណូលខ្លះសម្រាប់ អ្នកបម្រើការងារក្នុង រោងសិប្បកម្ម អាហារដ្ឋាន ឲ្យមានប្រាក់ខែសមរម្យ និងលើសពីនេះ គឺមានប្រាក់សម្រាប់បន្តគម្រោងនានាតទៅទៀត។ លោកអភិបាល "ទី១ គឺយើងឲ្យសិប្បកម្មមានកន្លែងលក់ ប៉ុន្តែអត់មាន(ត្រឹម)តែលក់(គឺ)ឲ្យយើងផ្សព្វផ្សាយ ដែលជនពិការមានសមត្ថភាពច្រើន។ ទីពីរឲ្យយើងអប់រំឲ្យកូនៗដែលធ្វើការនៅទីនេះ។ ហាងដែលមានម្ហូប និងមានសិប្បកម្ម ឲ្យគេរៀនរបៀបទំនាក់ទំនង និងឲ្យសង្គម ឬភ្ញៀវដែលមករៀន (ពីពួកគេ)។ ទីបី Social Enterprise (សហគ្រាសសង្គម) (បង្កើត)ឲ្យមានលុយខ្លះៗ។ យើងមានប្រាក់ខែសមរម្យ យើងផ្ដល់ឲ្យអ្នកធ្វើសិប្បកម្មទទួលតម្លៃត្រឹមត្រូវ។ អាហ្នឹងលុយដែលយើងរកឲ្យយើងមានដំណាក់កាលទៅខាងមុខ ហើយលុយដែលសល់ខ្លះ យើងមានសកម្មភាពផ្សេងៗ"។

លោកអភិបាលបានឲ្យដឹងទៀតថា ហាងកាហ្វេនេះបានជួយដល់សកម្មភាពរបស់ព្រះសហគមន៍យ៉ាងច្រើននៅក្នុងវិស័យសង្គមកិច្ច ជាពិសេសក្នុងកម្មវិធីអភិវឌ្ឍសហគមន៍និងអប់រំ គឺកម្មវិធីប្រព័ន្ធទឹកស្អាត និងកសាងបង្គន់អនាម័យតាមសាលារៀនជាដើម។

*ដោយកែវ កញ្ញា*

# ពិធីរំលឹកវិញ្ញាណក្ខន្ធជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្ម របបប៉ុលពត



ថតដោយ សម្បត្តិ

គ្រីស្តបរិស័ទជា២០០០នាក់ មកពីព្រះសហគមន៍នៅទូទាំងប្រទេសបានមកជួបជុំគ្នា ដើម្បីប្រារព្ធពិធីរំលឹកដល់វិញ្ញាណក្ខន្ធជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្មក្នុងរបបប៉ុលពត ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ កាលពីជាង៤០ឆ្នាំកន្លងទៅ។

ពិធីនេះរៀបចំក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់លោកកាឌីណាល់ លូវីសម៉ារីលីង ម៉ងខាណោឃួន ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគវៀងច័ន្ទនៃប្រទេសឡាវ លោកអភិបាលទាំងបីភូមិភាគ និងបូជាចារ្យជាច្រើននាក់ទៀត។

នៅពេលចាប់ផ្តើមកម្មវិធី លោកកាឌីណាល់ លោកអភិបាល និងលោកបូជាចារ្យ បានដង្ហែ ដោយរបាំត្រុដិឆ្មោះទៅកាន់ទីសក្ការៈ។ លោកអភិបាលអូលីវីយេ ឆ្មីតអីស្លែរ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគ ភ្នំពេញ មានប្រសាសន៍ស្វាគមន៍ លោកកាឌីណាល់ លូវីស ម៉ារីលីង ដែលជាតំណាងសម្តេចប៉ាបមកដល់ទឹកដីមរណសាក្សីនៅកម្ពុជា។ លោកអភិបាលបន្តថា "ថ្ងៃនេះយើងពោរពេញដោយអំណរសប្បាយជាមួយលោកកាឌីណាល់។ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់មរណសាក្សីដែលបានសាបព្រោះសម្រាប់ព្រះសហគមន៍ឡាវនិងកម្ពុជា ហើយក៏រំភើបដែរ និង ព្រួយចិត្តដែរ ដោយនឹករលឹកដល់បងប្អូន ខ្មែរយើងដែលបានទទួលមរណភាពជាងរាប់លាននាក់ នៅក្នុងសម័យប៉ុលពតដែលណែនាំឲ្យយើងនឹកឃើញដល់អំពើបាប ដែលជាប់នៅក្នុងដួងចិត្តយ៉ាងជ្រៅរបស់មនុស្សដែលនាំឲ្យយើងប៉ុន្មាន លើកប៉ុន្មានសារបាត់បង់សេចក្តីសង្ឃឹម"។

លោកអភិបាលមានប្រសាសន៍ថា "ពិតមែននៅថ្ងៃនេះ ព្រះសហគមន៍ចូលរួម ដើម្បីនឹករលឹកដល់វិញ្ញាណក្ខន្ធរបស់បងប្អូនទាំងអស់ ដែលបានមរណពីសម័យប៉ុលពត ហើយជាពិសេស ដើម្បីព្រះសហគមន៍យើង និងជាពិសេសដល់មរណសាក្សី ដែលជាតំណាងរបស់គ្រីស្តបរិស័ទ ដែលបានសុខចិត្ត លះបង់ចោលជីវិត បូជាជីវិតដើម្បីឲ្យយើងមានជីវិត"។

លោកអភិបាលអូលីវីយេ បានលើកបទពិសោធន៍របស់លោកកាឌីណាល់ដែលបានលះបង់ និងថ្វាយជីវិតរបស់លោកក្នុងពេលជាប់ឃុំឃាំង។ លោកអភិបាល "លោកកាឌីណាល់សួរពួកគេថា មូលហេតុអីខ្ញុំជាប់ឃុំឃាំង ខ្ញុំបានធ្វើអីខុស? គេឆ្លើយថា មកពីលោកបានផ្សព្វផ្សាយសាសនាយេស៊ូ។ ក្រោយមកគាត់ប្រាប់ថា ខ្ញុំអត់ដែលផ្សព្វផ្សាយ តែគេថា វត្តមានរបស់លោកបីដូចវត្តមានរបស់ព្រះយេស៊ូ"។

លោកអភិបាលបន្តថា ដូច្នេះវត្តមានរបស់លោកបូជាចារ្យ ប្រៀបដូចជាវត្តមានរបស់ព្រះយេស៊ូ។ លោកអភិបាលក៏សូមឲ្យគ្រីស្តបរិស័ទអធិដ្ឋាន សម្រាប់អស់អ្នកដែលបាន ស្លាប់នៅក្នុងពិភពលោកនេះ តែក៏ជាឱកាសមួយ ដើម្បីសំលឹងមើលជំនឿ ការអស្ចារ្យនៃជំនឿ។ ក្នុងរដូវបុណ្យ ចម្លងនេះ ជាពេលដែលយើង នឹកដល់ជីវិតដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញដែលនេះ ជាផ្លូវដែលមរណសាក្សីនៃព្រះសហគមន៍កម្ពុជា និងឡាវបានសម្រេចចិត្តរស់នៅក្នុងប្រទេសនៅពេលមានសង្គ្រាម ទោះបីគេមានឱកាសដើម្បីចាកចេញ។

ក្នុងឱកាសនោះដែរ លោកអភិបាលសូមឲ្យបងប្អូនគ្រីស្តបរិស័ទ ស្តាប់សំឡេងរបស់អស់អ្នក ដែលបានស្លាប់ក្នុងរបបនោះ ដែលមានលោកអភិបាលយ៉ូសែប ឆ្មារ សាឡាស លោកបូជាចារ្យឆ្មារ សាឡឹម និងបងស្រីលីឌីដែលបានផ្តល់នូវគំរូនិងពាក្យលើកទឹកចិត្តជាច្រើនសម្រាប់ព្រះសហគមន៍បច្ចុប្បន្ន។ លោកអភិបាលបានលើកទឹកចិត្តដោយលើកពីលិខិតដែលលោកអភិបាល យ៉ូសែប ឆ្មារ សាឡាស់ បានសរសេរមុនពេល លោកចាកចេញពីប្រទេសបារាំងត្រលប់មកកម្ពុជាវិញ មុនថ្ងៃទី១៧ ខែមេសា ១៩៧៥ថា "ខ្ញុំសូមផ្ញើអនាគតរបស់ខ្ញុំទៅព្រះជាម្ចាស់ សូមឲ្យអនាគតរបស់ខ្ញុំដើរលើផ្លូវអស់កល្បជានិច្ច"។ លោកអភិបាលអូលីវីយេបន្ថែមថា "ពេលយើង កំពុងជួបទុក្ខលំបាក ពេលយើងកំពុងរងទុក្ខវេទនា។ នៅពេលនោះជំនឿទៅជាកម្លាំងណែនាំឲ្យយើងទទួលជីវិត និងកំលាំងយ៉ាងពិសេស ដើម្បីឲ្យយើងរួមគ្នាអាចបង្កើតពិភពថ្មីដែលល្អជាងថ្ងៃនេះសម្រាប់កូនចៅរបស់យើង សម្រាប់បងប្អូនរបស់យើង"។

នាឱកាសនោះលោក កាឌីណាល់លីវីស ម៉ារីលីង ម៉ងខាណោឃួន មានប្រសាសន៍លើកទឹកចិត្តដល់គ្រីស្តបរិស័ទឲ្យយកចិត្តទុកដាក់អំពីវត្តមានរបស់ព្រះយេស៊ូដែលប្រទានជីវិតឲ្យយើង។ លោកកាឌីណាល់បានពន្យល់ទៀតថា ទុក្ខលំបាកនៃជំនឿដែលគ្រីស្តបរិស័ទជួយយើងគឺឲ្យយើងចូលទៅក្នុងមហាគ្រួសារនៃព្រះសហគមន៍ ដោយសារពិធីជ្រមុជទឹក ទោះបីជាជាតិសាសន៍ណាក៏ដោយ។

ក្នុងសម័យប៉ុលពត ព្រះសហគមន៍កាតូលិកក៏ដូចជាសាសនាដទៃទៀតដែលមាននៅក្នុងប្រទេសកម្ពុជា បានទទួលរងគ្រោះជាខ្លាំងទាំងទ្រព្យសម្បត្តិ និងធនធានមនុស្សបាត់បង់ស្ទើរតែទាំងស្រុង ដោយមាន លោកអភិបាល បូជាចារ្យ និងបងស្រី រួមនិងគ្រីស្តបរិស័ទ។

ព្រះសហគមន៍នៅកម្ពុជា បានរស់ឡើងវិញ ក្នុងទសវត្ស១៩៩០ បច្ចុប្បន្នមានបូជាចារ្យជាតិខ្មែរចំនួន៩នាក់ ក្នុងចំណោមសាសនទូតជិត២០០នាក់ ដែលកំពុងបម្រើព្រះសហគមន៍ និងមានគ្រីស្តបរិស័ទជាងពីរម៉ឺននាក់៕

*ដោយ កែវ កញ្ញា*

# ពិធីសច្ចានិរន្តន៍ និងដំបូងរបស់ដូនជីក្រុមស្រឡាញ់ឈើឆ្កាងព្រះយេស៊ូ

ចម្រៀងតម្កើងព្រះជាម្ចាស់ និងការប្រកាសការថ្វាយខ្លួនរបស់ក្រុមបព្វជិតាដែលបានបន្លឺឡើងក្នុងពិធីអរព្រះគុណព្រះជាម្ចាស់ នៃការថ្វាយពាក្យសច្ចាប្រណិធានជានិរន្តរ៍ និងដំបូងរបស់ដូនជីក្រុមបងស្រីស្រឡាញ់ ឆ្កាងព្រះយេស៊ូ នៅព្រះសហគមន៍កាតូលិក កំពង់ចាមក្រុង ដោយមានលោកកាឌីណាល់ លូវីស ម៉ារីលីង ម៉ងខាណោឃូន ជាអភិបាលនៃភូមិភាគវៀងច័ន្ទ ប្រទេសឡាវ រួមនឹងលោកអភិបាលទាំងបីភូមិភាគ បូជាចារ្យ និងគ្រីស្តបរិស័ទជាច្រើនកុះករ នាព្រឹកថ្ងៃទី៣ឧសភាឆ្នាំ២០១៨នេះ។

កម្មវិធីបានចាប់ផ្តើមដោយមានក្បួនដង្ហែនាំមុខដោយរបាំក្មេងពត់ពែនតាមចង្វាក់ភ្លេងជាពីរជួរ ដែលតាមពីក្រោយដោយក្បួនបងស្រី ក្រុមលោកបូចារ្យជាច្រើននាក់និងអភិបាល ដោយមានលោកកាឌីណាល់ លូវីស ម៉ារីលីង នៅខាងក្រោយ។ បន្ទាប់ពីអានអត្ថបទគម្ពីររួចមក លោកអភិបាល អេនរីគេ ហ្វីការេដូ អភិហាលនព្ទេះសហគមន៍កាតូលិកភូមិភាគបាត់ដំបងបានធ្វើធម្មទេសនានាឱកាសនោះថា បងស្រីបានជ្រើសរើសស្រឡាញ់ ព្រះយេស៊ូដោយបានចូលរួមក្នុងក្រុម។ លោកអភិបាលបានបន្តថា ការត្រាស់ហៅនេះ គឺអស់មួយជីវិត។ ព្រះជាម្ចាស់ប្រទានឲ្យមានការត្រាស់ គឺឲ្យមានភក្តី ភាពចំពោះព្រះអង្គដែលបានបូជាជីវិតនៅលើឈើឆ្កាង។ ក្នុងពិធីនេះ មានការសច្ចាប្រណិធាននិរន្តរ៍ គឺបងស្រី ម៉ារី ម៉ាដាឡា ញឹប សុខនី និងការសច្ចា ប្រណិធានដំបូង គឺបងស្រីថេរេសា ចាន់រដ្ឋា និងបងស្រីក្លារ៉ា ពេនហ៊ីល។ លោកអភិបាល អេនរីគេបន្តថា ដើម្បីឲ្យការត្រាស់ហៅនេះបានជាប់រហូត បងស្រីទាំងអស់ត្រូវអធិដ្ឋាន អានគម្ពីរ និងត្រូវអនុវត្តតាមព្រះហឫទ័យព្រះជាម្ចាស់ ដោយស្រឡាញ់ដូចព្រះយេស៊ូ មានចិត្តទូលំលាយ មានមេត្តាករុណានិងអាណិតអាសូរ។ លោកអភិបាលក៏សូមឲ្យបងស្រីយកគំរូរបស់សន្តីបុគ្គលដែលជាឧបការីរបស់បងស្រីទាំងអស់ និងយកគំរូ របស់ព្រះនាងម៉ារីដែលជាមាតារបស់ព្រះសហគមន៍ដែលណែនាំជាគំរូសម្រាប់គ្រីស្តបរិស័ទ។ លោកក៏បានផ្តាំផ្ញើដល់បងស្រីឲ្យស្រឡាញ់ព្រះជាម្ចាស់រហូតដល់ឈើ។ នេះជាសេចក្តីស្រឡាញ់ដែលអស់ពីចិត្ត ដែលនៅជាប់ជាមួយនឹងព្រះយេស៊ូ។ ត្រូវស្រឡាញ់ព្រះយេស៊ូ ដោយបម្រើអ្នកដទៃ លើកទឹកចិត្តគេ និយាយពាក្យពីរោះៗ បម្រើបងប្អូន ដោយបន្ទាបខ្លួន ដោយសុភាពរាបសារ ដូចព្រះនាងម៉ារីនិងព្រះយេស៊ូ តាមមាគ៌ារបស់ព្រះជាម្ចាស់។

បន្ទាប់ពីធម្មទេសនា លោកអភិបាលបានហៅបងស្រីទាំងអស់ដែលនឹងថ្វាយពាក្យសច្ចាឲ្យមកខាងមុខព្រះសហគមន៍ដើម្បីបង្ហាញខ្លួន និងប្រកាសពាក្យសន្យារបស់ខ្លួន។

បងស្រីហ៊ីលបេក្ខនារី ថ្វាយពាក្យសច្ចាប្រណិធានដំបូង មានប្រសាសន៍ថា ជីវិតជាអ្នកបួសមិនងាយស្រួល ប៉ុន្តែការទុកចិត្តលើព្រះជាម្ចាស់គឺ ជារឿងសំខាន់ ព្រោះព្រះជាម្ចាស់ គង់នៅជាមួយនឹងយុំគ្រងរហូត។

បងស្រីពេនហ៊ីលគឺជាកូនស្រីក្នុងគ្រួសារគ្រីស្តបរិស័ទដែលមានដើមកំណើតជាជនជាតិដើមភាគតិចពូណង។ បងស្រីបន្ថែមថា ការជ្រើសរើសផ្លូវនេះបងស្រីបានទទួលការបដិសេធពីសំណាក់ក្រុមគ្រួសារជាខ្លាំង នេះដោយសារតែម្តាយឪពុកមានការភ័យខ្លាច។ ម្យ៉ាងទៀតតាមទម្លាប់បងប្អូនជនជាតិគឺមិនមាននរណាចូលបួសទេ។តែដោយការពន្យល់ពីបងស្រីផ្ទាល់ គឺសូមឲ្យម្តាយឪពុកទុកចិត្តទៅលើព្រះជាម្ចាស់។ បងស្រីបាននិយាយពាក្យមួយឃ្លាថា "រូបកាយរបស់ខ្ញុំ ម្តាយឪពុកជាអ្នកបង្កើតពិតមែន តែជីវិតខាងផ្លូវវិញ្ញាណរបស់ខ្ញុំ គឺព្រះជាម្ចាស់ជាអ្នកផ្តល់ឲ្យ"។នៅទីបំផុតឪពុកម្តាយនិងបងប្អូនបានយល់ព្រម តាមការស្នើសុំរបស់បងស្រី គឺជាផលផ្លែនៃការអធិដ្ឋាននិងជាអំណរសប្បាយមកពីព្រះជាម្ចាស់យ៉ាងពិតប្រាកដ។ បងស្រីបានបន្តថាទោះបីការរៀនបួសរយៈពេល៤ឆ្នាំមានការលំបាកបន្តិចក៏ដោយ តែដោយសេចក្តីស្រឡាញ់បងស្រីអាចបន្តមកដល់ជំហាននេះ។

ចំណែកបងស្រីម៉ារីម៉ាដាឡា ញឹប សុខនីដែលបានថ្វាយពាក្យសច្ចាជានិរន្តរ៍បានឲ្យដឹងថា ទោះបីជាក្នុងផ្លូវជីវិតជាអ្នកបួសនេះគឺមានការលំបាកខ្លះៗតែខ្ញុំនៅតែអាចបន្តរទៅមុខទៀតបានដោយសារតែការអធិដ្ឋាន។ ពេលខ្លះខ្ញុំអស់កម្លាំងក្នុងការបំពេញកិច្ចការផ្សេងៗ តែការអធិដ្ឋាន បានផ្តល់កម្លាំងខាងផ្លូវវិញ្ញាណឲ្យខ្ញុំក្រោកឡើងហើយបន្តរដំណើរទៅមុខទៀត។ បងស្រីបន្តថា "ខ្ញុំមិនដែលមានអារម្មណ៍ថាឯកោនោះទេ ដោយសារតែផ្លូវនេះមិនមែនមាន តែខ្ញុំម្នាក់ឯងទេ គឺមានបងស្រីជាច្រើន ទៀតកំពុងរួមដំណើរជាមួយដែរ។ បងស្រីបន្ថែមថា៖ មូលហេតុ ដែលខ្ញុំសម្រេចចិត្តប្រកាសពាក្យសច្ចាជានិរន្តរ៍នេះ គឺមានន័យថាខ្ញុំបានផ្ញើជីវិតនិងអ្វីៗគ្រប់យ៉ាងទៅតាមគម្រោងការណ៍របស់ព្រះជាម្ចាស់។ ហេតុនេះ ចំពោះយុវជនយុវនារីដែលមានបំណងចង់ឈ្វេងយល់អំពីជីវិតអ្នកបួសនេះ សូមកុំខ្លាច ត្រូវក្លាហានឆ្លើយតបចំពោះការត្រាស់ហៅនេះ។ យើងត្រូវដឹងថា មានរៀមច្បងជាច្រើននាក់រួចហើយដែលដើរផ្លូវនេះ ហេតុនេះសូមកុំខ្លាចអី សូមព្យាយាមអធិដ្ឋាននោះ ព្រះជាម្ចាស់និងផ្តល់កម្លាំងចិត្តឲ្យយើងគ្រប់ពេល។

នៅក្នុងពិធីថ្វាយ ពាក្យសច្ចាប្រណិធាននេះ បងស្រីជាតិខ្មែរដែលបានថ្វាយពាក្យសច្ចាប្រណិធាននិរន្តរ៍កាលពីប៉ុន្មានឆ្នាំមុន ក៏បានបង្ហាញអំពីឆន្ទៈរបស់ខ្លួនក្នុងការរក្សាចិត្តស្មោះត្រង់ ភក្តីភាពចំពោះការថ្វាយខ្លួននេះ នៅចំពោះព្រះសហគមន៍របស់ព្រះជាម្ចាស់ ដោយរស់នៅលីវអស់មួយជីវិត រក្សាព្រហ្មចារីធម៌ និងស្តាប់បង្គាប់ប្រធានក្រុមគ្រួសារ។ ក្រុមបងស្រីស្រឡាញ់ព្រះយេស៊ូដែលបានបូជាព្រះជន្មនៅលើឈើឆ្កាងបង្កើតឡើងដោយដោយលោកអភិបាល ឡាំប៊ែរដឺឡាមុតក្នុងឆ្នាំ ១៦៧០។ មានវត្តមាននៅប្រទេសកម្ពុជា ១៧៧២នៅប្រាំបីឆោម។ ប៉ុន្តែអ្វីត្រូវបានបំផ្លូវគ្មានសល់ដោយពួកអាវខ្មៅប៉ុលពត១៩៧៥ដល់១៩៧៩។ ដោយកល្បប្រឹក្ស




ថតដោយ សម្បត្តិ

សន្ត បុគ្គល


សន្ត សិលា ក្លាវីរ

លោកសិលា ក្លាវីរ ជាបព្វជិតជនជាតិអេស្ប៉ាញ ក្នុងក្រុមគ្រួសារសហជីវិនព្រះយេស៊ូ (Jesuit)។ គេបញ្ជូនគាត់ទៅអាមេរិកខាងត្បូង ជាកន្លែង ដែលគាត់ចំណាយពេល៤០ឆ្នាំ ដើម្បីជួយរំដោះជនជាតិអាហ្វ្រិកក្នុងភាពជាទាសកររបស់ពួកគេ។ គាត់ហៅខ្លួនឯងថា ខ្ញុំនៃទាសករ។ គាត់ធ្វើជាគ្រីស្តទូត ឪពុក គ្រូពេទ្យ និងមិត្តសម្លាញ់របស់ពួកគេទាំងអស់គ្នា។ ពេលទទួលដំណឹងថា មាននាវាដឹកទាសករ ជិតមកដល់កំពង់ផែ សិលានឹងទៅទទួលស្វាគមន៍ពួកគេភ្លាម ហើយជួយសម្រាលទុក្ខទាសករទាំងអស់នោះ។ គាត់បានឲ្យចំណីអាហារ និងសម្លៀកបំពាក់ដល់ពួកគេ ហើយជួយថែរក្សាពួកគេឲ្យរួចផុតពីជំងឺ។ គាត់បានធ្វើពិធីជ្រមុជទឹកឲ្យទាសករ ៤០០០នាក់។ លោកសិលាមានប្រសាសន៍ថា៖ យើងត្រូវតែជួយទាសករច្រើនជាងនិយាយអំពីភាពធ្វើជាទាសករ។ លោកមិនប្រកាន់អ្នកមាន ហើយគាត់សុំជំនួយពីពួកអភិជនដែរ ដើម្បីបង្កើតអង្គការជាច្រើនជួយពួកទាសករ។ លោកសិលាបានប្រកាស ដំណឹងល្អដល់ទាសករជាអ្នកក្រីក្របំផុតនៅក្នុងសង្គម ដោយយកឋានៈធ្វើជាទាសករដែរ ដូចព្រះយេស៊ូផ្ទាល់ខ្លួនបានលះបង់ឋានៈរបស់ខ្លួនជាព្រះជាម្ចាស់ដើម្បីប្រសូត្រជាមនុស្ស។

ដោយសារសកម្មភាពរបស់លោក លោកបានក្លាយជាឧបការីនៃទាសករនៃសាធារណរដ្ឋប្រទេសកូឡុំប៊ី និងក្រសួងជនជាតិអាមេរិកអាហ្វ្រិក៕

# ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រា ៤២**

អ្នកកាន់បណ្ណបើកបរគ្រប់ប្រភេទមានសិទ្ធិបើកបរយានយន្តរហូតដល់អាយុ ៦៥ (ហុកសិបប្រាំ) ឆ្នាំ។ ចាប់ពីអាយុ ៦៥(ហុកសិបប្រាំ) ឆ្នាំឡើងទៅ អ្នកកាន់បណ្ណបើកបរអាចអនុញ្ញាតឲ្យបើកបរបាន ប៉ុន្តែត្រូវពិនិត្យសុខភាពនិងប្តូរបណ្ណបើកបរដែលមានសុពលភាពរយៈពេល ២(ពីរ)ឆ្នាំម្តង ។

សុពលភាពនៃប្រភេទបណ្ណបើកបរ ក ខ គ ឃ និង ង មានរយៈពេល ដូចខាងក្រោម៖

១.បណ្ណបើកបរប្រភេទ ក និងប្រភេទ ខ មានសុពលភាពរយៈពេល ១០ (ដប់) ឆ្នាំ ។

២.បណ្ណបើកបរប្រភេទ គ ឃ និង ង មានសុពលភាពរយៈពេល ៥ (ប្រាំ) ឆ្នាំ ។

៣.អ្នកកាន់បណ្ណបើកបរត្រូវសុំប្តូរបណ្ណបើកបរមុនអស់សុពលភាព ដោយភ្ជាប់មកជាមួយនូវលិខិតពិនិត្យសុខភាពដែលបញ្ជាក់ថាអាចបើកបរបាន។ ការមិន បានប្តូរបណ្ណបើកបរថ្មីត្រូវទទួលការពិន័យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

ការពិនិត្យសុខភាពត្រូវមានលិខិតបញ្ជាក់ថា អាចបើកបរបានពីគ្រូពេទ្យនៅតាមមន្ទីរពេទ្យ ឬ មណ្ឌលសុខភាពដែលត្រូវកំណត់ដោយក្រសួងសុខាភិបាល។

**មាត្រា ៤៣**

គ្រប់បណ្ណបើកបរត្រូវមានបណ្ណពិន្ទុដែលមានពិន្ទុសរុបចំនួន១២(ដប់ពីរ) ពិន្ទុ ហើយចំនួនពិន្ទុនេះត្រូវកាត់បន្ថយនៅពេលប្រព្រឹត្តបទល្មើសចរាចរណ៍ ដូចខាងក្រោម ៖

ក.ត្រូវកាត់បន្ថយ ១ (មួយ) ពិន្ទុ ៖

- មិនពាក់ខ្សែក្រវ៉ាត់ ឬមួកសុវត្ថិភាព
- ប្រើភ្លើងហ្វានៅពេលជួបនឹងយានមកពីទិសផ្ទុយ
- បើកបរជាន់តាមខ្សែគំនូសបង្កួតកណ្តាលទ្រូងផ្លូវ
- បើកបរលើសល្បឿនកំណត់ចាប់ពី១(មួយ)ទៅ១៩(ដប់ប្រាំបួន) គីឡូម៉ែត្រក្នុងមួយម៉ោង
- ផ្ទុកមនុស្សលើសកំណត់ ។

ខ.ត្រូវកាត់បន្ថយ ២ (ពីរ) ពិន្ទុ ៖

- បើកបរលើសល្បឿនកំណត់ចាប់ពី ២០ (ម្ភៃ) ទៅ ២៩ (ម្ភៃប្រាំបួន) គីឡូម៉ែត្រក្នុងមួយម៉ោង
- បើកបរបង្កើនល្បឿននៅពេលគេកំពុងជែងខ្លួន
- បត់ឆ្វេង ស្តាំ មិនបានត្រឹមត្រូវ
- បត់ត្រឡប់ក្រោយនៅកន្លែងហាមឃាត់
- មិនគោរពលក្ខខណ្ឌនៃប័ណ្ណបើកបរ
- បត់ឆ្វេង ស្តាំ ឬឈប់មិនបានឲ្យសញ្ញាជាដំណឹង
- ជែង ឬជៀសមិនបានត្រឹមត្រូវ
- បើកបរដោយគ្មានទុកចន្លោះសុវត្ថិភាពគ្រប់គ្រាន់ដែលបង្កឲ្យមានគ្រោះថ្នាក់
- បើកបរដោយធ្វេសប្រហែស ធ្វើឲ្យរំខានអ្នកប្រើប្រាស់ផ្លូវដទៃទៀត
- មិនបាឲ្យសញ្ញាជាដំណឹងត្រឹមត្រូវនៅពេលចេញដំណើរ
- យានមានលក្ខណៈបច្ចេកទេសមិនត្រឹមត្រូវ
- ផ្ទុកទំនិញមិនបានត្រឹមត្រូវ
- ចតយាននៅលើគំនូសសម្រាប់ថ្មើរជើងឆ្លងកាត់
- ឈប់ ឬចតនៅលើគំនូសតម្រឹមទ្រូងផ្លូវ
- ដាក់កុមារអាយុ ១០(ដប់)ឆ្នាំ ឲ្យអង្គុយនៅកៅអីផ្នែកខាងមុខនៃរថយន្ត
- មិនបានដាក់កុមារអាយុក្រោម៥(ប្រាំ)ឆ្នាំឲ្យអង្គុយក្នុងកៅអីសម្រាប់កុមារអង្គុយ ឬ ដេកក្នុងរថយន្ត
- គេចពីមន្ត្រីនគរបាលចរាចរណ៍ដែលធ្វើការត្រួតពិនិត្យ

គ.ត្រូវកាត់បន្ថយ ៣ (បី) ពិន្ទុ ៖

- ឈប់ ឬចតនៅកន្លែងដែលគ្រោះថ្នាក់
- ជែងដែលប្រកបដោយគ្រោះថ្នាក់
- បើកបរជែងគ្នានៅកន្លែងហាមឃាត់
- ប្តូរទិសគ្មានឲ្យសញ្ញាជាដំណឹង
- បើកបរឆ្លងកាត់គំនូសបង្កួតជាប់កណ្តាលទ្រូងផ្លូវ
- បើកបរលើសល្បឿនកំណត់ចាប់ពី៣០(សាមសិប)ទៅ៣៩(សាមសិបប្រាំបួន) គីឡូម៉ែត្រក្នុងមួយម៉ោង
- បើកបរក្នុងពេលមានអត្រាជាតិស្រវឹងចាប់ពី ០,២៥ (សូន្យក្បៀសម្ភៃប្រាំ) ទៅ ០,៣៩ (សូន្យក្បៀសហាមសិប្រាំបួន) ក្រាមក្នុងមួយលីត្រឈាម
- បើកបរប្រណាំងគ្នាតាមផ្លូវដោយគ្មានច្បាប់អនុញ្ញាត
- កំហុសនៃការឈប់ ឬការមិនផ្តល់សិទ្ធិអាទិភាពនៅកន្លែងថ្មើរជើងឆ្លងកាត់
- មិនគោរពស្លាកសញ្ញាឈប់ ឬសញ្ញាសិទ្ធិអាទិភាព
- មិនគោរពសញ្ញាបញ្ជាចរាចរណ៍របស់នគរបាលចរាចរណ៍

ឃ.ត្រូវថកាត់បន្ថយ ៤ (បួន) ពិន្ទុ ៖

- បើកបថរលើសល្បឿនកំណត់ចាប់ពី ៤០(សែសិប)ទៅ៤៩(សែសិបប្រាំបួន) ទៅ ៤៩ (សែសិបប្រាំបួន) គីឡូម៉ែត្រក្នុងមួយម៉ោង
- បើកបរមិនគោរពសិទ្ធិអាទិភាពនៅត្រង់ផ្លូវប្រសព្វ
- បើកបរទទឹមគ្នា
- ធ្វើឲ្យស្ទះចរន្តចរាចរណ៍
- មិនបានផ្តល់សិទ្ធិអាទិភាពឲ្យយានយន្តមានសិទ្ធិអាទិភាព
- ទំនិញធ្លាក់ពីលើយានពេលកំពុងបបើកបរ
- បើកបរបញ្ច្រាសទិសចរាចរណ៍
- បើកបរង្កោះ រេចុះឡើង ឆាបឬក្បៀ ។

ង.ត្រូវបន្ថយ ៦ (ប្រាំមួយ) ពិន្ទុ ៖

- បើកបថរលើសល្បឿនកំណត់ចាប់ពី៥០(ហាសិប)គីឡូម៉ែត្រក្នុងមួយម៉ោងឡើង
- បើកបរក្នុងពេលមានអត្រាជាតោស្រវឹងចាប់ពី ០,៤០ (សូន្យក្បៀសសែសិប) មីលីក្រាមក្នុងមួយលីត្រខ្យល់ ឬចាប់ពី ០.៨០ (សូន្យក្បៀសប៉ែតសិប) ក្រាមក្នុងមួយលីត្រឈាមឡើងទៅ ឬមានឥទ្ធិពលគ្រឿងញៀន
- រត់គេចខ្លួនពេលមានគ្រោះថ្នាក់ចរាចរណ៍
- ប្រើប្រាស់ផ្លាកលេខ និងបណ្ណសម្គាល់យានយន្តក្លែងក្លាយ
- បើកបរល្មើសច្បាប់ចរាចរណ៍ហើយបង្កឲ្យមានរបួសដល់អ្នកដទៃដោយអចេតនា ហើយបណ្តាលឲ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើ ឬលើសពី ៨ (ប្រាំបី) ថ្ងៃ គិតពីថ្ងៃកើតហេតុ ឬស្លាប់
- កំហុសមិងរាងចាលនៃការប្រើប្រាស់បណ្ណបើកបរហួសសុពលភាព ឬមិនត្រឹមត្រូវតាមប្រភេទយាន
- បដិសេធមិនឲ្យធ្វើតេស្តជាតិអាល់កុល ឬសារធាតុញៀន
- ផ្ទុកមនុស្សលើទំនិញ ។

ក្នុងករណីប្រព្រឹត្តបទល្មើសម្តង ការកាត់ពិន្ទុមិនត្រូវឲ្យលើសពី៨(ប្រាំបី)ពិន្ទុឡើយ៕

# ២៥ឆ្នាំ បេសកកម្មក្នុងក្រុមបព្វជិតមេត្តាករុណា


ថតដោយ សុធិរិទ្ធ

អស់រយៈកាល២៥ឆ្នាំដែលបងប្រុសមេត្តាករុណា២រូបបានបន្តពាក្យសច្ចារបស់ខ្លួនក្នុងក្រុមបព្វជិតមេត្តាករុណា ដែលត្រូវបានប្រកាសជាថ្មីម្តងទៀត កាលពីថ្ងៃទី១៩ ឧសភា ២០១៨ ដោយមានលោក អភិបាលអូលីវីយេ ដ្មីតអីស្លែរ ជាអធិបតី និងមានតំណាងគ្រីស្តបរិស័ទមួយចំនួនផង នៅគ្រឹះស្ថានបងប្រុសមេ-ត្តាករុណា ក្នុងសង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ។

បងប្រុស ហាម៉ាន់ (Br. Herman Soreng)និង បងប្រុស យ៉ូទី(Br.Jyo-tiNinj) បានឡើងអុជទៀនចំនួន២៥ដើម ដែលតំណាងឲ្យរយៈពេលនៃបេស-កកម្មរបស់បងប្រុសដើម្បីប្រារព្ធពិធីបុណ្យអភិបូជាលើកតម្កើងសិរីរុងរឿង និងអរព្រះគុណព្រះជាម្ចាស់។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍នៅក្នុងធម្មទេសនានៃពិធីបុណ្យអភិបូជាថា អ្នកមានក្តី អ្នកក្រក្តី តែងតែចង់បានក្តីសុខ តែខុសគ្នាត្រង់មធ្យោបាយដែលជ្រើសរើសក្នុងជីវិត។ លោកបន្តថា ថ្ងៃនេះយើងឃើញថាបងប្រុសមានផ្លូវមួយដែលនាំឲ្យជីវិតមានក្តីសុខ។

លោកអភិបាលបន្ថែមទៀតថា ថ្ងៃនេះយើងមានគំរូពិសេសសម្រាប់យើងគឺបងប្រុសបានស្ម័គ្រចិត្តធ្វើជាបព្វជិត ដោយមានគោលបំណងតែមួយ ដើម្បីស្វែងរកសុភមង្គល គឺព្រះជាម្ចាស់។ លោកបន្តថា ជីវិតរបស់យើងមិនអាចមានសុភ-មង្គលត្រឹមតែទ្រព្យសម្បត្តិលោកីយ៍តែប៉ុណ្ណោះតែមានសុភមង្គលនៅពេលដែលយើងបានរកឃើញអត្ថន័យនៃជីវិត គឺលែងមានចិត្តអាត្មានិយមដែលនាំឲ្យអ្នកដទៃមានសុភមង្គល។ លោកអភិបាលបញ្ជាក់ថា សេចក្តីស្រឡាញ់ជាផ្លូវ ដើម្បីនាំឲ្យមនុស្សមានសុភមង្គលនិងរកឃើញព្រះជាម្ចាស់។

បងប្រុសយ៉ូទី(ពន្លឺ)បានឲ្យដឹងតាមរយៈបទសម្ភាសអំពីបទពិសោធន៍នៃអំណរសប្បាយដែលបានសច្ចាជាបង-ប្រុសនៅក្នុងក្រុមគ្រួសារមេត្តាករុណារយៈពេល២៥ឆ្នាំនេះគឺការជួយអ្នកក្រីក្ររស់នៅជាមួយអ្នកក្រីក្រដែលជាអំណរសប្បាយជាងគេនៅក្នុងជីវិត។

បងប្រុស ហាម៉ាន់ និងបងប្រុស យ៉ូទី បានថ្វាយពាក្យសច្ចាក្នុងក្រុមគ្រួសារមេ-ត្តាករុណា នៅឆ្នាំ១៩៩៣ នៅប្រទេសឥណ្ឌា។

ក្រុមបងប្រុសមេត្តាករុណា បានចូលមកក្នុងប្រទេសកម្ពុជារយៈពេល១២ឆ្នាំមកហើយ ដើម្បីបម្រើព្រះសហគមន៍ បម្រើអ្នកក្រីក្រនៅប្រទេសកម្ពុជា។ ហើយនេះជាឆ្នាំទី៧របស់បងប្រុសទាំងពីររូបដែលពួកគាត់បានមកបំពេញបេសកកម្មនៅប្រទេសកម្ពុជាដោយបងប្រុសបានចូលរួមសកម្មភាពជាច្រើននៅក្នុងសង្គម ដូចជាជួយអ្នកក្រីក្រឲ្យមានអំណរ-សប្បាយ សួរសុខទុក្ខលើកទឹកចិត្តអ្នកអស់សង្ឃឹម និងចែកអំណោយដល់អ្នកក្រីក្រ សួរសុខទុក្ខថែទាំអ្នកជំងឺនិងចែកថ្នាំដល់អ្នកជំងឺ ឧបត្ថម្ភការសិក្សាដល់កុមារកំព្រា ជាពិសេសទៅសួរសុខទុក្ខជនជាប់ឃុំឃាំង ជារៀងរាល់ពីរសប្តាហ៍ម្តង ដើម្បីបង្ហាញពីវត្តមានរបស់ព្រះយេ-ស៊ូ និងវត្តមានរបស់ព្រះជាម្ចាស់ដល់បងប្អូនឯទៀត ព្រោះព្រះជាម្ចាស់ជា សេចក្តីស្រឡាញ់។

ក្រុមគ្រួសារបងប្រុសមេត្តករុណា គឺជាបព្វជិតកាតូលិក បានបង្កើតឡើងក្នុងឆ្នាំ១៩៦៣ ដោយអ្នកម្តាយតេរេសានៃក្រុងកាល់គូថា បន្ទាប់ពីអ្នកម្តាយបានបង្កើតក្រុមបព្វជិតាមេត្តាករុណា ក្នុងឆ្នាំ១៩៥០។ ក្រុមគ្រួសារបងប្រុស រស់តាមផ្លូវវិញ្ញាណនៃអ្នកម្តាយតេរេសានៃក្រុងកាល់គូថាប្រទេសឥណ្ឌា។ សមាជិកទាំងអស់ប្រកាសពាក្យសច្ចាដោយប្រកាន់យកជីវិត៖ រស់ជាអ្នកក្រីក្រ កាន់ព្រហ្ម-ចារីធម៌ ស្តាប់បង្គាប់ និងបម្រើអស់ពីដួងចិត្តនិងឥតគិតថ្លៃចំពោះអ្នកក្រីក្របំផុត។

*ដោយដាលីស*

# ព្រះនាងម៉ារីជាព្រះមាតាព្រះអម្ចាស់ និងជាមាតាព្រះសហគមន៍

ក្នុងឆ្នាំ២០១៨នេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានប្រកាសដាក់បញ្ចូលបុណ្យគោរពព្រះនាងម៉ារី ជាមាតា នៃព្រះសហគមន៍ ទៅក្នុងប្រតិទិន របស់ព្រះសហគមន៍ ដោយកំណត់ យកមួយថ្ងៃក្រោយថ្ងៃបុណ្យព្រះវិញ្ញាណយាងមក ជារៀងរាល់ ឆ្នាំ។

ក្នុងនោះដែរព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ប្រារព្ធពិធីបុណ្យគោរពព្រះនាងម៉ារីជាព្រះមាតានៃព្រះសហគមន៍កាតូលិកយ៉ាងឱឡារិក នៅព្រះវិហារព្រះមាតានៃសន្តិភាព (អរិយក្សត្រ) នាព្រឹកថ្ងៃទី២១ ឧសភា ២០១៨ ក្រោមអធិបតីភាពលោកអូលីវីយេ ដ្មីតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងមានគ្រីស្តបរិស័ទ មកពីព្រះ-សហគមន៍នានាចូលរួមជាច្រើនកុះករ។

លោកអភិបាលអូលីវីយេ ដ្មីតអីស្លែរ បានមានប្រសាសន៍ថា ព្រះនាងម៉ារីជាមាតារបស់ព្រះអម្ចាស់ នៅពេលដែលទេវទូតមកប្រាប់ដំណឹង អំពីកំណើតព្រះយេស៊ូ ហើយព្រះនាងជាម្តាយរបស់ព្រះសហគមន៍គឺនៅពេលដែល ព្រះយេស៊ូនៅលើឈើឆ្កាង។ ព្រះអង្គបានផ្តាំទៅព្រះនាងម៉ារីឲ្យទទួលលោកយ៉ូហានដែលតំណាងក្រុមគ្រីស្តទូត និងជាព្រះសហគមន៍ធ្វើជាកូន ហើយបានផ្តាំទៅលោកយ៉ូហានឲ្យទទួលព្រះនាងម៉ារីជាម្តាយ។

លោកអភិបាលបានបន្ថែមទៀតថា៖ "ព្រះសហគមន៍ត្រូវការមាតា ដែលថែរក្សា និងផ្តល់ភាពកក់ក្តៅ ដឹងពីទុក្ខលំបាករបស់កូន និងចាប់អារម្មណ៍ពីកូនម្នាក់ៗ ដោយមិនបោះបង់ចោលកូន ទោះបីជាកូនធ្វើអ្វីខុសក៏ដោយ"។ លោកសង្កត់ធ្ងន់ថា "ម្តាយដែលបោះបង់ចោលកូនគឺជាម្តាយមិនគ្រប់ទឹក"។ ប៉ុន្តែព្រះនាងម៉ារីមិនដែលបោះបង់ចោលយើង ដែលជាព្រះសហគមន៍នោះទេ។

លោកអូលីវីយេ ក៏មានប្រសាសន៍លើកទឹកចិត្តដល់គ្រីស្តបរិស័ទទាំងអស់ទៀតថា ព្រះនាងម៉ារីបានចូលនៅក្នុងព្រះហឫទ័យ នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ដោយព្រះជាម្ចាស់បានលើកព្រះនាងម៉ារីឡើងស្ថានបរមសុខទាំងរូបកាយ និងវិញ្ញាណ។ លោកថា៖ នេះបង្ហាញថា ព្រះនាងម៉ារីនៅកណ្តាលរវាងស្ថានបរមសុខ និងពិភពលោក ព្រមទាំងចាប់ដៃយើង ឲ្យមានភាពកក់ក្តៅ ក្នុងការធ្វើដំណើរ បន្តិចម្តងៗ ដើម្បីចូលទៅក្នុងព្រះហឫទ័យនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។

ក្រោយអភិបូជា គ្រីស្តបរិស័ទទាំងអស់ បានច្រៀងកោតសើសើរព្រះនាងម៉ារី និងអធិដ្ឋាន នៅលើភ្នំព្រះនាងម៉ារី សូមឲ្យមនុស្សលោកទាំងអស់ ជាពិសេសម្តាយទាំងអស់ ក្រុមគ្រួសារទាំងអស់ និងប្រជាជនកម្ពុជាទាំងឡាយ ព្រមទាំងព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ទទួលបានសេចក្តីសុខសាន្ត៕


ថតដោយ សុធិរិទ្ធ

# លោកអភិបាលជំរុញឲ្យបេក្ខជនលាបថ្ងាសចូលរួមនៅក្នុងសង្គម ដោយអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់




*ថតដោយៈ សម្បត្តិ*

គ្រីស្តបរិស័ទ៣០នាក់មកពីសហគមន៍កាតូលិកនិយាយភាសាអង់គ្លេស សហគមន៍កាតូលិកនិយាយភាសាកូរ៉េ និង ព្រះវិហារសន្តយ៉ូសែប បានទទួលអគ្គសញ្ញាលាបថ្ងាស ក្នុងពិធីបុណ្យព្រះវិញ្ញាណយាងមក។ ពិធីនេះប្រារព្ធទៅកាលពីព្រឹកថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៨ ក្រោមវត្តមាន លោកអភិបាល អូលីវីយេ ដ្មឺតអឺ ស្លឺរនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញជាអធិបតី នៅព្រះវិហារសន្តយ៉ូសែបផ្សារតូចភ្នំពេញ និងមានគ្រីស្តបរិស័ទ ចូលរួមប្រមាណមួយពាន់នាក់ដែលមានជាតិសាសន៍ផ្សេងមានដូចជា ខ្មែរ កូរ៉េ បារាំង អាមេរិក ឥណ្ឌា ហ្វីលីពីន ថៃ ប៉ាគីស្ថាន អាហ្វ្រិក ចិន ជប៉ុន វៀតណាម ។ល។

លោកអភិបាលអូលីវីយេមានប្រសាសន៍ទៅកាន់ បេក្ខជនទាំង៣០នាក់ឲ្យខិតខំធ្វើជាគ្រីស្តបរិស័ទសកម្ម ដោយការអធិដ្ឋាន និង ចូលរួមសកម្មភាពតាមក្រុមនីមួយៗរបស់ព្រះសហគមន៍ ព្រមទាំងទទួលអគ្គសញ្ញានានា ជាពិសេសសូមចូលរួមនៅក្នុងសង្គម ដោយអនុវត្តតាមព្រះបន្ទូល "សូមស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ"។

លោកបន្តថា ការអនុវត្តតាមព្រះបន្ទូលនឹងណែនាំឲ្យយើងអាច ចូលរួមនៅក្នុងសង្គម ដោយមានសកម្មភាពប្រកបទៅដោយសេចក្តីពិត មានយុត្តិធម៌ គោរពបរិស្ថាន គោរពគ្នាទៅវិញទៅមក ព្រោះព្រះជាម្ចាស់ ជាសេចក្តីស្រឡាញ់។ លោកអភិបាលក៏មានប្រសាសន៍ទៀតថា ប្រសិនបើយើងអនុវត្តតាមនេះ នោះប្រៀបដូចមេឃងងឹតដែលអាចភ្លឺបាន ដោយពន្លឺផ្កាយ ហើយផ្កាយនីមួយៗមានឈ្មោះ របស់វា គឺ "ខ្ញុំ"។

នៅក្នុងធម្មទេសនាដដែលនេះលោកអភិបាលបានលើកឡើងថា ព្រះវិញ្ញាណដ៏វិសុទ្ធដែលយើងទទួលគឺជាព្រះវិញ្ញាណនៃសេចក្តីពិត ដែលណែនាំឲ្យយើងជួបសេចក្តីពិតពេញលក្ខណៈ និងជាពន្លឺនៃសេចក្តីពិតដែលធ្វើឲ្យយើងនឹកឃើញ ដល់ប្រវត្តិសាស្ត្រ(អតីតកាល) និងអាចមើលឃើញពីអនាគត ដើម្បីធ្វើដំណើរក្នុងពេលបច្ចុប្បន្ននេះទៅកាន់អនាគតកាលដោយសេចក្តីពិត។

លោកបន្តថា ព្រះវិញ្ញាណដ៏វិសុទ្ធនាំឲ្យយើងនឹកឃើញពីប្រវត្តិសាស្ត្រនៃពិភពលោកទាំងមូលដែលបានធ្វើឡើងដោយអំណរសប្បាយ និងការអស្ចារ្យតាមរយៈការអភិវឌ្ឍពីមួយជំនាន់ទៅមួយជំនាន់។ លោកបន្ថែមថា ថ្ងៃនេះទី២០ ខែឧសភា រាជរដ្ឋាភិបាលកម្ពុជាប្រារព្ធទិវាចងចាំ ហើយសម្រាប់យើងជាគ្រីស្តបរិស័ទ គឺជាពេលវេលាមួយឲ្យយើងរួមគ្នា ដើម្បីប្រកាសថាយើងជាសាវ័ករបស់ព្រះយេស៊ូ ប្រកបដោយយុត្តិធម៌ សេចក្តីស្រឡាញ់ អំណរសប្បាយ សេចក្តីពិតដែលបំផ្លាញនូវរាល់អំពើអាក្រក់ទាំងឡាយ និងសង្គ្រាម ដើម្បីរស់នៅក្នុងជីវិតថ្មី (ក្នុងព្រះជាម្ចាស់)។

ក្រោយបញ្ចប់ធម្មទេសនា ព្រះសហគមន៍ បានប្រកាសឲ្យបេក្ខជន ត្រៀមខ្លួននឹងទទួលអគ្គសញ្ញា ដោយប្រកាសពីជំនឿផ្ទាល់ខ្លួននៅចំពោះមុខព្រះសហគមន៍ និងក្រាបខ្លួនអធិដ្ឋាន រួមជាមួយលោកអភិបាល ដើម្បីទូលអង្វរព្រះជាម្ចាស់តាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធ។ បេក្ខជនទាំង៣០រូប បានឡើងទទួលអគ្គសញ្ញាលាបថ្ងាស ពីលោកអភិបាលអូលីវីយេ ដោយយកប្រេងគ្រីស្មាគូសជាសញ្ញាឈើឆ្កាងតាមប្រពៃណីព្រះសហគមន៍កាតូលិក។

បន្ទាប់មកតំណាងគ្រីស្តបរិស័ទក៏បានទូលអង្វរព្រះជាម្ចាស់តាមរយៈធម៌សកលជាភាសាផ្សេងៗពីគ្នា មានដូចជា ខ្មែរ កូរ៉េ វៀតណាម បារាំង អង់គ្លេស ឥណ្ឌា ចិន ប៉ាគីស្ថាន ហ្វីលីពីន ថៃ ជាដើម ដើម្បីបង្ហាញថាមនុស្សលោកទាំងអស់គឺជាមហាគ្រួសារតែមួយ ជាព្រះសហគមន៍តែមួយ ទោះបីមានជាតិ សាសន៍ខុសគ្នាក៏ដោយ ហើយក៏ស្របតាមអត្ថបទព្រះគម្ពីរដំណឹងល្អដែលមានគ្រីស្តទូត ចេញទៅប្រកាសដំណឹងល្អជាភាសាផ្សេងៗគ្នាក្រោយពេលទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។

យុវនារី ម៉ារី ហោ ផល្លីកា បាននិយាយថា "សម្រាប់ខ្ញុំយល់ថា ព្រះវិញ្ញាណដ៏វិសុទ្ធនឹងជួយឲ្យខ្ញុំមានយោបល់ល្អ មានអំណរសប្បាយ មានសេចក្តីក្លាហានគោរពកោតខ្លាចព្រះជាម្ចាស់ និងធ្វើជាគ្រីស្តបរិស័ទពេញលេញ ដោយធ្វើតាមការណែនាំរបស់ព្រះវិញ្ញាណ ព្រមទាំងឲ្យខ្ញុំចេះគិតពិចារណាដឹងខុសដឹងត្រូវ"។ កញ្ញាបន្តថា ការទទួលព្រះវិញ្ញាណនៅថ្ងៃនេះពិតជាមានសារៈសំខាន់ និងជួយឲ្យខ្ញុំមានភាពក្លាហានប្រកាសដំណឹងល្អដោយចូលរួមជាមួយក្រុមយុវជនរបស់ព្រះសហគមន៍ ដើម្បីជួយដល់សង្គមជាពិសេសជនពិការ និងអ្នកក្រីក្រ ព្រមទាំងអ្នកជំងឺនៅក្នុងព្រះសហគមន៍ផ្ទាល់។

ពិធីលាបថ្ងាសធ្វើឲ្យព្រះអំណោយទាននៃពិធីជ្រមុជទឹកបានពេញលក្ខណៈ គឺអគ្គសញ្ញានេះផ្តល់ព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីឲ្យយើងចាក់ឫសយ៉ាងជ្រៅក្នុងពូជពង្សជាបុត្រធីតារបស់ព្រះជាម្ចាស់ ឲ្យគ្រីស្តបរិស័ទរួមជាមួយព្រះគ្រីស្តនិងព្រះសហគមន៍យ៉ាងជិតស្និទ្ធនិងមាំមួន ចូលរួមក្នុងបេសកកម្មរបស់ព្រះសហគមន៍ច្រើនជាងមុន ដោយធ្វើជាសាក្សីតាមពាក្យសំដីផងនិងកិច្ចការផង។

*ដោយដាលីស*

## សម្តេចប៉ាបៈ សេចក្តីស្រលាញ់អាចជួយកាត់បន្ថយហានិភ័យនៃជំងឺនិងសេចក្តីស្លាប់

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានឲ្យដឹងថា សេចក្តីស្រលាញ់ជាទូទៅអាចជាឱសថដែលអាចមានអត្ថប្រយោជន៍ដល់សុខភាពជាពិសេសគឺអាចកាត់បន្ថយហានិភ័យនៃជំងឺនិងសេចក្តីភ័យខ្លាចនៃសេចក្តីស្លាប់ដែលមនុស្សគ្រប់ៗគ្នាត្រូវតែជួប។

យោងទៅតាមទីភ្នាក់ងារព័ត៌មានកាតូលិក សម្តេចប៉ាបបានថ្លែងថា នៅក្នុងចំណោម សេចក្តីស្រលាញ់ទាំងនោះ គឺសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ គឺរឹតតែមានតម្លៃសម្រាប់គ្រីស្តបរិស័ទទាំងអស់។

សម្តេចប៉ាបបានថ្លែងថា នៅដំណាក់កាលចុងក្រោយនៃជីវិតរបស់មនុស្សម្នាក់ៗនៅលើលោកនេះ ជាទូទៅសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ គឺមានអត្ថន័យបំផុតសម្រាប់ពួកគេ ។

សម្តេចប៉ាបបានថ្លែងបញ្ជាក់នៅថ្ងៃទី០៦ ខែឧសភាថា សេចក្តីស្រលាញ់ចំពោះអ្នកដទៃ គឺមិនអាចបម្រុងទុកបានទាំងអស់ទេសម្រាប់មនុស្សជាតិ ប៉ុន្តែព្រះជាម្ចាស់គឺអាចជួយបំពេញសម្រាប់គ្រីស្តបរិស័ទទាំងអស់ ។

លោកបន្តថាមនុស្សម្នាក់ ប្រសិនបើមានស្ថានភាពដល់ដំណាក់កាលចុងក្រោយហើយនោះ គឺត្រូវតែរិះគិតគ្រប់វិធីសាស្ត្រទាំងអស់ដើម្បីសង្គ្រោះពួកគេ ជាពិសេស គឺសេចក្តីស្រលាញ់ គឺត្រូវតែការពារឲ្យខានតែបាន។ សម្តេចប៉ាបបានថ្លែងថា គ្រីស្តបរិស័ទទាំងអស់ គឺត្រូវតែយកចិត្តទុកដាក់គ្រប់សកម្មភាពទាំងអស់ ដើម្បីទទួលបាននូវក្តីស្រលាញ់ពីព្រះជាម្ចាស់ដ៏ពិតប្រាកដ។ សម្តេចប៉ាបបានថ្លែងទៀតថា សេចក្តីស្រលាញ់គឺជាឱសថសម្រាប់ការពារចាស់ព្រឹទ្ធាចារ្យ និងលើកទឹកចិត្តបណ្តុះក្តីស្រលាញ់របស់គេ៕

## ព្រះសហគមន៍នៅវៀតណាមរៀបចំរំលឹកការតែងតាំងមរណសាក្សី

បណ្តាញព័ត៌មានយូខេនញូវ បានអះអាងថា ក្រុមសភាលោកអគ្គអភិបាលនៃព្រះសហគមន៍នៅវៀតណាមបានរៀបចំពិធីរំលឹកដល់ការលះបង់របស់អស់បងប្អូន ដែលត្រូវបានតែងតាំង ជាមរណសាក្សី ។

ប្រភពដដែលបានបន្តថា វៀតណាមមានមរណសាក្សីប្រមាណជា ១១៧នាក់ ដែលត្រូវបាន បុរីវ៉ាទីកង់ទទួលស្គាល់ថាគឺជាអ្នកដែលបាន បាត់បង់ជីវិតដោយសារការបៀតបៀនព្រោះតែជំនឿ ។

ប្រភពដដែលបានបន្តថា នេះគឺជាខួបលើកទី៣០ឆ្នាំនៃការបាត់បង់ជីវិតគ្រីស្តបរិស័ទនៅវៀតណាមទាំង១១៧នាក់។

លោកអគ្គអភិបាល យ៉ូសែប ឃ្វៀនជីលិញ ប្រធានសភាលោកអភិបាលព្រះសហគមន៍វៀតណាម បានអះអាងថា នេះគឺជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍នៅវៀតណាម ។

លោកបានបន្តថា ដើម្បីរំលឹកដល់បណ្តាមរណសាក្សីទាំងនេះ ព្រះសហគមន៍វៀតណាម នឹងរៀបចំព្រឹត្តិការណ៍នៅកន្លែងប្រវត្តិសាស្ត្របីកន្លែង ។

លោកអគ្គអភិបាលនៃព្រះសហគមន៍ នៅវៀតណាមក៏បានថ្លែងទៀតថា សូមគ្រីស្តបរិស័ទវៀតណាមទាំងអស់រស់នៅក្នុងជំនឿតាមគំរូរបស់មរណសាក្សីទាំងអស់ដោយលើកទឹកចិត្តគ្រីស្តបរិស័ទ សួរសុខទុក្ខដល់ទុគ៌តជន អ្នកជំងឺ ជនងាយរងគ្រោះ អ្នកទោស និងចាស់ជរា ដែលគ្មានសាច់ញាតិ៕

## សម្តេចប៉ាបពន្យារអាណត្តិដល់បេសកជនបុរីវ៉ាទីកង់ ប្រចាំនៅ ម៉ាលតា

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ត្រូវបានទីភ្នាក់ងារព័ត៌មានកាតូលិករាយការណ៍នៅសប្តាហ៍មុនថា បានសម្រេចចិត្តពន្យាបេសកជនរបស់បុរីវ៉ាទីកង់ ប្រចាំនៅប្រទេសម៉ាល់តា។

ទីភ្នាក់ងារព័ត៌មានកាតូលិក បានអះអាងថា លោកអគ្គអភិបាល ជីអូវ៉ានី អេនជីឡូ បេឃ្យូ ត្រូវបានសម្តេចប៉ាបសម្រេចពន្យាពេល១៥ខែ បន្ថែមទៀតនៅក្នុងការសម្រេចចិត្តមួយរបស់សម្តេចប៉ាបកាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨ ។

ប្រភពដដែលបានអះអាងថា សម្តេចប៉ាបបានសម្រេចពន្យាពេល ជូនលោកអគ្គអភិបាលក្រោយពេលដែល លោកអគ្គអភិបាលសម្រេចទទួលការស្នើសុំពន្យាពេលពីសម្តេចប៉ាប ។

សម្តេចប៉ាបបានវាយតម្លៃខ្ពស់ចំពោះប្រសិទ្ធិភាព និងទម្រង់ការរបស់លោកអគ្គអភិបាល ដូច្នេះហើយបានជាមានការសម្រេចចិត្ត ឲ្យលោកអគ្គអភិបាលបន្តការងារជាតំណាងរបស់បុរីវ៉ាទីកង់បន្ថែមទៀត។

លោកអគ្គអភិបាលបានទទួលការតែងតាំង ជាបេសកជនរបស់បុរីវ៉ាទីកង់ប្រចាំនៅប្រទេសនេះ ពីឆ្នាំ២០១១ នៅក្នុងនាមជាបេសកជនពិសេស ដើម្បីជួយកិច្ចការកំណែទម្រង់មួយចំនួននៅក្នុងព្រះសហគមន៍ ក៏ដូចជាបញ្ហាសង្គមនៅក្នុងប្រទេសនេះ។

ប្រទេសម៉ាលតាគឺជាដែនដីកោះដ៏តូចមួយ មានប្រជាពលរដ្ឋមិនដល់មួយលាននាក់ផង៕

## ដូនជីជាតិអូស្រ្តាលី នឹងតស៊ូប្រឈមនឹងការអះអាងរបស់រដ្ឋាភិបាលហ្វីលីពីន

បងស្រី ប៉ាទ្រីសា ហ្វុក ដែលត្រូវបានរដ្ឋបាលប្រធានាធិបតីហ្វីលីពីន លោក រ៉ូឌ្រីហ្គោ ដូតឺតេ បណ្តេញចេញពីប្រទេសដោយសារតែសកម្មភាពមួយចំនួនរបស់បងស្រី ប៉ុន្តែទោះបីជាយ៉ាងណាបងស្រីបានអះអាងថា បងស្រី នឹងប្រឈមមុខតវ៉ានឹងការចោទប្រកាន់របស់រដ្ឋាភិបាលហ្វីលីពីន ។

បងស្រីនឹងត្រៀមប្រមូលឯកសារ ដែលមានរហូតដល់ទី២៥ទំព័រ សម្រាប់ដាក់ជូន ការិយាល័យអន្តោប្រវេសន៍ហ្វីលីពីន។

បងស្រី ប៉ាទ្រីសា ហ្វុក ត្រូវបានគេដឹងថាបានរស់នៅនិងបម្រើព្រះសហគមន៍កាតូលិក នៅក្នុងប្រទេសហ្វីលីពីនរហូតដល់ទៅ២៧ឆ្នាំ។

បងស្រីបានអះអាងថា អាជ្ញាធរហ្វីលីពីន គឺមិនមានសិទ្ធិកំណត់ ឬមិនកំណត់អំពីព្រំដែន ឬកំណត់ទំហំកិច្ចការ មនុស្សធម៌ ឬបេសកកម្មរបស់ព្រះសហគមន៍បាននោះទេ។ អាជ្ញាធរហ្វីលីពីន គួរតែមានការពិភាក្សាជាមួយ នឹងថ្នាក់ដឹកនាំព្រះសហគមន៍។

អាជ្ញាធរហ្វីលីពីន បានចោទប្រកាន់បងស្រី ប៉ាទ្រីសា ហ្វុក ពីបទថាបាន ប្រឹងប្រែងបកស្រាយ ចំណុចមួយចំនួន ដែលនឹងបង្កផលប៉ះពាល់ ឬរំលោភកិច្ចការអាជ្ញាធរ ជាពិសេស គឺទាក់ទងនឹងសេរីភាព សាសនា និងជំនឿផ្សេងៗ។

ដូនជី ប៉ាទ្រីសា ហ្វុក មានអាយុ៧១ឆ្នាំ បានអះអាងថាអាជ្ញាធរគួរតែមានការប្រឹក្សាយោបល់ជាមួយ បូជាចារ្យ បព្វជិត-ជិតា សម្រាប់កិច្ចការមនុស្សធម៌នានា។ ដោយសារតែការចោទប្រកាន់នេះ បងស្រីត្រូវបានអាជ្ញាធរហ្វីលីពីនលុបចោលទិដ្ឋាការនាថ្ងៃទី ២៣ ខែ មេសា មកម្ល៉េះ៕

## សម្តេចប៉ាបប្រកាសឈ្មោះកាឌីណាល់ថ្មីចំនួន ១៤ រូប

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃទី២០ ខែ ឧសភា បានប្រកាសឈ្មោះកាឌីណាល់ថ្មីចំនួន ១៤ រូប តែងតាំងនៅក្នុងរង្វង់ថ្ងៃទី២៩ ខែមិថុនា ខាងមុខនេះ។

វ៉ាទីកង់ញូវ បានរាយការណ៍ថា សម្តេចប៉ាប បានប្រកាសបែបនេះ គឺនៅក្នុងពេលដែល សម្តេចស្វាគមន៍គ្រីស្តបរិស័ទដែលបានមកចូលរួម ធម្មយាត្រា ហើយបានប្រមូលផ្តុំគ្នា នៅខាងមុខទីលានវិសាលវិហារសន្តសិលា កាលពីថ្ងៃអាទិត្យ កន្លងទៅនេះ ។

នេះគឺជាការប្រកាសដ៏ភ្ញាក់ផ្អើលមួយ បន្ទាប់ពីសម្តេចប៉ាបបានថ្លែងអប់រំជំនឿជូនគ្រីស្តបរិស័ទ ដោយសម្តេចប៉ាបបានប្រកាសថា ការតែងតាំងនេះ គឺដើម្បីធ្វើឲ្យព្រះសហគមន៍កាតូលិក កាន់តែសកម្ម ដើម្បីបន្តមាគ៌ាផ្សព្វផ្សាយអំពីសេចក្តីស្រលាញ់ និង ប្រកាសដំណឹងល្អទៅដល់បងប្អូននៅលើពិភពលោកនេះ ។

ប្រភពដដែលបានបន្តថាបណ្តាអភិបាលដែលនឹងទទួលនូវមួកពណ៌ក្រហម ពីសម្តេចប៉ាប គឺរួមមាន អភិបាលនៃព្រះសហគមន៍មកពីអ៊ីរ៉ាក់ ប៉ាគីស្ថាន ព័រទុយហ្គាល់ ប៉េរូ ម៉ាដាហ្គាស្កា និងពីជប៉ុន។ ក្រៅពីនោះ ក៏មានលោកអគ្គអភិបាលជនជាតិប៉ូឡូញ និងអ៊ីតាលីបីរូបផងដែរ៕

# សម្តេចប៉ាបសុំឲ្យសភាលោកអភិបាលផ្អាកការទទួលព្រះកាយរបស់អ្នករៀបការអន្តជំនឿ

លិខិតមួយពីក្រសួងសម្រាប់គោលលទ្ធិនៃជំនឿកាតូលិក បានបង្ហាញពន្លឺនៅលើជំហររបស់សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ទាក់ទងនឹងការទទួលព្រះកាយព្រះគ្រីស្តរបស់គ្រីស្តបរិស័ទពីក្រុមជំនុំប្រូតេស្តង់ នៅក្នុងពិធីអភិបូជាសម្រាប់អគ្គសញ្ញាអាពាហ៍ពិពាហ៍អន្តរជំនឿរវាងគ្រីស្តបរិស័ទកាតូលិក និងប្រូតេស្តង់។ បញ្ហានេះត្រូវបានលើកឡើងដោយសភាលោកអភិបាលអាល្លឺម៉ង់ គឺបានលើកឡើងអំពីប្រធានបទរួមគ្នារិះគិតអំពីព្រះសហគមន៍សកល។

ក្នុងលិខិតនោះ សម្តេចប៉ាបបានឲ្យដឹងថា ការទទួលព្រះកាយព្រះគ្រីស្តរបស់គ្រីស្តបរិស័ទប្រូតេស្តង់ដែលបានរៀបការជាមួយគ្រីស្តបរិស័ទកាតូលិក ទាមទារឲ្យមានការសិក្សាបន្ថែម។

សារព័ត៌មានវ៉ាទីកង់ញូវ បានឲ្យដឹងថា សម្តេចប៉ាបហ្វ្រង់ស៊ីស្កូបានសូមឲ្យលោកអភិបាលអាល្លឺម៉ង់រង់ចាំច្បាប់ ដែលអាចអនុវត្តជាសកល ដែលបានចោទសួរក្នុងការអនុញ្ញាតឱ្យពួកប្រូតេស្តង់ដែលបានរៀបការជាមួយកាតូលិកទទួលបានព្រះកាយព្រះគ្រីស្តក្នុងពិធីអភិបូជារបស់ព្រះសហគមន៍កាតូលិក។ ការលើកឡើងបែបនេះនៅក្នុងលិខិតមួយរបស់ក្រសួងគោលលទ្ធិនៃជំនឿកាតូលិកដោយលោកអគ្គរាជទូតលូវីស ឡាដារៀ ក្នុងនាមសម្តេចប៉ាប ផ្ញើទៅកាន់ប្រធានក្រុមលោកអភិបាលនៃប្រទេសអាល្លឺម៉ង់ គឺលោកកាឌីណាល់ រ៉េនហាដ ម៉ាកស្ស៍ (Reinhard Marx)។ លិខិតនេះគូសបញ្ជាក់អំពីតម្រូវការចាំបាច់ដើម្បីវាយតម្លៃដោយប្រុងប្រយ័ត្ននូវផលវិបាកនិងផលប៉ះពាល់ ដែលកើតឡើងពីការសម្រេចចិត្តណាមួយ អាចមានសមភាពក្នុងការសន្ទនាគ្នាជាអន្តរជំនឿ។

នៅក្នុងពិធីបុណ្យរបស់ព្រះសហគមន៍កាតូលិក ការទទួលព្រះកាយព្រះគ្រីស្តគឺជាអគ្គសញ្ញាមួយដ៏វិសុទ្ធ សម្រាប់តែអ្នកដែលបានទទួលពិធីជ្រមុជទឹកក្នុងព្រះវិហារកាតូលិកប៉ុណ្ណោះ។

តាមសារព័ត៌មានដដែលនេះបានបង្ហាញថា ក្រុមលោកអភិបាលកាតូលិកអាល្លឺម៉ង់ ហាក់មានជំហរវិជ្ជមានក្នុងការផ្តល់ព្រះកាយព្រះគ្រីស្តដល់គ្រីស្តបរិស័ទប្រូតេស្តង់ដែលបានរៀបការជាមួយគ្រីស្តបរិស័ទកាតូលិក ហើយពេលខ្លះក៏មានព្រះលោកហិត ព្រះគ្រីស្តដែលបានប្រសិទ្ធិពររួចផងដែរ៕





# ពាក្យអធិដ្ឋានរបស់សម្តេចប៉ាប សម្រាប់ខែមិថុនា

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ក្នុងខែមិថុនានេះ បានផ្ញើសារជាវីដេអូមួយ ស្តីអំពីបណ្តាញទំនាក់ទំនងសង្គម អាចធ្វើការឆ្ពោះទៅរកការរួបរួមគ្នា ដោយគោរពអ្នកដទៃទោះបីគេមានគំនិតខុសគ្នា។

នៅលើទំព័រសារព័ត៌មានរបស់វ៉ាទីកង់ញូវ ចុះកាលពីថ្ងៃទី៥មិថុនានេះ បានបង្ហោះវីដេអូឃ្លីបមួយរបស់សម្តេចប៉ាបដែលនេះ ជាសារអធិដ្ឋានសម្រាប់ខែមិថុនានេះ។ សម្តេចប៉ាបមានប្រសាសន៍ថា អ៊ីនធឺណែតគឺជាអំណោយទានមួយរបស់ព្រះជាម្ចាស់ប៉ុន្តែវាក៏ជាការទទួលខុសត្រូវដ៏ខ្ពស់មួយផងដែរ។ បច្ចេកវិទ្យាទំនាក់ទំនង កន្លែងរបស់វា ឧបករណ៍របស់វា បាននាំមកនូវចំណេះដឹង និងការពង្រីកដ៏ទូលំទូលាយមួយសម្រាប់មនុស្សជាច្រើន។ វាអាចផ្តល់នូវលទ្ធភាពធំធេងសម្រាប់ជំនួបនានា និងសាមគ្គីភាព។ សូមឲ្យបណ្តាញឌីជីថលនេះ មិនមែនជាកន្លែងផ្តាច់ខ្លួននោះទេ។ សូមឱ្យវាក្លាយជាកន្លែងជាក់លាក់មួយ និងពោរពេញដោយសេចក្តីថ្លៃថ្នូរនៃមនុស្សជាតិ។ ចូរយើងអធិស្ឋានជាមួយគ្នា សូមឲ្យបណ្តាញសង្គមអាចធ្វើការឆ្ពោះទៅរកការរួមបញ្ចូលគ្នា ដែលគោរពគ្នាទៅវិញទៅមកទោះបីមានគំនិតខុសគ្នា៕

# ក្រសួងបីប្រកាសចាត់វិធានការអ្នកប្រើប្រាស់អ៊ីនធឺណែតណាដែលល្មើសច្បាប់

នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ថ្មីៗនេះ ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសនីយ៍និងទូរគមនាគមន៍ បានចេញសេចក្តីប្រកាសរួមគ្នាមួយស្តីពីការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធើណែត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សេចក្តីប្រកាសនេះបានលើកឡើងពីគោលបំណងដូចមានចែងនៅក្នុងប្រការទី១ថា ប្រកាសនេះមានគោលបំណងគ្រប់គ្រងការផ្សព្វផ្សាយរាល់ខ្លឹមសារព័ត៌មាន ឬសារជាអក្សរ សំលេង រូបភាព វីដេអូ និងឬទម្រង់ផ្សេងៗទៀត តាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការលើប្រព័ន្ធអ៊ីនធើណែតនៅក្នុងព្រះរាជាណាចក្រកម្ពុជាស្របតាមអនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាននិងច្បាប់ស្តីពីរបបសារព័ត៌មាន។ ប្រការទី២បានចែងថា ប្រកាសនេះមានគោលដៅប្រឆាំងទប់ស្កាត់រាល់ការផ្សព្វផ្សាយ ឬចែកចាយខ្លឹមសារព័ត៌មាន ឬសារជាអក្សរ សំលេង រូបភាព វីដេអូ ឬទម្រង់ផ្សេងៗទៀត ដែលមានចេតនាបង្កជាចលាចល បណ្តាលឲ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ប្រពៃណីជាតិ។ ចំពោះវិធានផ្លូវច្បាប់គឺសាមីក្រសួងនីមួយៗនឹងចាត់វិធានការតាមផ្លូវច្បាប់ចំពោះបទល្មើសក្នុងដែនសមត្ថកិច្ចរបស់ខ្លួន គឺក្រសួងព័ត៌មានចាត់វិធានការផ្លូវច្បាប់ចំពោះស្ថានប័ននានា ដែលទទួលការអនុញ្ញាតពីក្រសួងព័ត៌មាន។ព្រមទាំងផ្តល់ព័ត៌មានទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីបិទគេហទំព័រ ឬ pageបណ្តាញសង្គមនោះ។ចំពោះក្រសួងប្រៃសណីយ៍ត្រូវគ្រប់គ្រង និងចាត់វិធានការចំពោះបទល្មើសនោះ បើក្រុមហ៊ុននៅក្រោមក្រសួងនេះ។ ចំពោះក្រសួងមហាផ្ទៃមានតួនាទីធ្វើការសិក្សា ស្វែងរកប្រភពគេហទំព័រ និងបណ្តាញសង្គមដែលផ្សព្វផ្សាយល្មើសច្បាប់ ដែលមានចេតនាបង្កជាចលាចល




បណ្តាលឲ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ប្រពៃណីជាតិដើម្បីចាត់វិធានការតាមនិតិវិធីច្បាប់។ សេចក្តីប្រកាសនេះ បានបញ្ជាក់យ៉ាងច្បាស់នូវកាលបរិច្ឆេទសម្រាប់អនុវត្ត គឺចាប់ពីពេលចុះហត្ថលេខានេះតទៅ៕

ដោយលី សុវណ្ណា

## សកម្មភាពកីឡាពានរង្វាន់ លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ






## សកម្មភាពកីឡាពានរង្វាន់ លោកអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង





Radio Veritas Asia

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

# វិទ្យុវេរីតាស់អាស៊ីខេមរភាសា

## សំឡេងពីព្រះសហគមន៍កាតូលិកកម្ពុជា

**វិទ្យុវេរីតាស់អាស៊ី ជាខេមរភាសា ផ្សាយរៀងរាល់ថ្ងៃ លើស្ថានីយ៍វិទ្យុ FM នៅភ្នំពេញ និងតាមបណ្ដាខេត្តមួយចំនួន តាមពេលវេលាដូចខាងក្រោម៖**

| | | |
|---|---|---|
| ភ្នំពេញ | : FM 103 Mhz | ម៉ោង ៨:០០- ៩:០០ យប់ |
| បាត់ដំបង | : FM 91 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងសៀមរាប | : FM 100.5 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |
| ក្រុងស្ទឹងសែន ខេត្តកំពង់ធំ | : FM 103.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ក្រុងកំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ យប់ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ យប់ |
| ក្រុងកំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រសៀល |

- លោកអ្នកក៏អាចស្ដាប់កម្មវិធីផ្សាយរបស់វិទ្យុវេរីតាស់អាស៊ី ខេមរភាសានៅលើគេហទំព័រ

www.rvakhmer.com, www.catholiccambodia.org

-លោកអ្នក ក៏អាច Follow face book ផ្លូវការរបស់យើង https://www.facebook.com/RVAKHMER/

**✣ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង**

លោកអ្នកអាចស្ដាប់កម្មវិធីវិទ្យុវេរីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Varitas Asia

Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com